# បទពិសោធន៍អន្តរជាតិអំពី

# រ៉េដបូក និង មូលនិធិព្រៃឈើអន្តរជាតិ



## ការកាត់បន្ថយបរិមាណឧស្ម័នបំភាយពីព្រៃនៅអាស៊ី (LEAF)

# បទពិសោធន៍អន្តរជាតិអំពីរ៉េដបូក និង មូលនិធិព្រៃឈើអន្តរជាតិ


រៀបរៀងដោយ

Darragh Conway
Luke Pritchard
Charlotte Streck

ពិនិត្យកែសម្រួលដោយ៖

Charlie Parker
Jeremy Broadhead

កម្មវិធីកាត់បន្ថយការបំភាយឧស្ម័នពីព្រៃឈើនៅអាស៊ី (LEAF) ដែលជាកិច្ចព្រមព្រៀងសហប្រតិបត្តិការសម្រាប់រយៈពេល ៥ ឆ្នាំ បានទទួលមូលនិធិគាំទ្រពីបេសកកម្មអភិវឌ្ឍន៍ប្រចាំតំបន់អាស៊ី (RDMA) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ(USAID)។ LEAF កំពុងស្ថិតក្នុងការអនុវត្តដោយអង្គការវីនរ៉ក់អន្តរជាតិ (Winrock) ក្រោមភាពជាដៃគូជាមួយ SNV - អង្គការអភិវឌ្ឍន៍ហូឡង់ ដែលផ្តោតលើការងារអាកាសធាតុ - និងមជ្ឈមណ្ឌលដើម្បីមនុស្សនិងព្រៃឈើ(RECOFTC)។ កម្មវិធី LEAF បានចាប់ផ្តើមនៅឆ្នាំ ២០១១ និងត្រូវបន្តរហូតដល់ឆ្នាំ ២០១៦។

# មាតិកាអត្ថបទ

**១. សេចក្តីផ្តើម** ........ 5

១.១ សាវតា ........ 5

១.២ តួនាទី និងមុខងាររបស់មូលនិធិរ៉េដបូក ........ 6

**២. ការប្រៀបធៀបបទពិសោធន៍ជាមួយមូលនិធិអន្តរជាតិ** ........ 8

២.១ រចនាសម្ព័ន្ធមូលនិធិ ........ 12

២.២ អភិបាលកិច្ច និងការគ្រប់គ្រងមូលនិធិ ........ 13

២.៣ ការវិនិយោគធនធានពីមូលនិធិ ........ 16

២.៤ ភាពសមស្រប និងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស ........ 17

២.៥ ការវាយតម្លៃ និង MRV ........ 19

២.៦ ប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថាន ........ 21

២.៧ លក្ខខណ្ឌជាក់លាក់របស់ម្ចាស់ជំនួយ ........ 22

**ឧបសម្ព័ន្ធ ១. សេចក្តីពិពណ៌នា និងការវិភាគមូលនិធិ**

**ឧបសម្ព័ន្ធ ២. សញ្ញាណ និងនិយមន័យសំខាន់ៗ**

# សេចក្តីផ្តើម

## ១.១ សាវតា

នៅសម័យប្រជុំលើកទី ១៦ នៃសន្និសីទភាគី (COP16) ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ភាគីនានាបានឯកភាពអនុវត្តរេដបូកតាមរយៈវិធីសាស្ត្រជាជំណាក់កាល ដែលចាប់ផ្តើមដោយសកម្មភាពត្រៀមលក្ខណៈ មុននឹងឈានទៅអនុវត្តសកម្មភាពបង្ហាញដែលផ្អែកលើលទ្ធផល និងនៅទីបំផុត ការអនុវត្តសកម្មភាពផ្អែកតាមលទ្ធផលនិងដែលអាចវាស់បាន អាចរាយការណ៍បាននិងអាចផ្ទៀងផ្ទាត់បាន(MRV)។ ទោះបីមួយផ្នែកធំនៃសកម្មភាពរេដបូកនៅកម្រិតពិភពលោកមកទល់ពេលនេះ បានផ្តោតលើសកម្មភាពត្រៀមលក្ខណៈក៏ដោយ ប្រទេសជាច្រើនបានងាកទៅអនុវត្តសាកល្បងវិធានបង់ថ្លៃទៅតាមលទ្ធផល ដែលតម្រូវឲ្យមានការបង្កើតវិធីប្រកបដោយប្រសិទ្ធភាព និងដែលផ្តល់ផល សម្រាប់ការទទួល ការគ្រប់គ្រង និងការផ្ទេរសាច់ប្រាក់សម្រាប់ការបង់ថ្លៃនោះ។

កិច្ចប្រឹងប្រែងអនុវត្តរេដបូកនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ បន្តរីកចម្រើននៅអាស៊ីអាគ្នេយ៍។ ឆ្នាំ ២០១៣ ឃើញថាប្រទេសវៀតណាមក្លាយជាប្រទេសដំបូងនៅក្នុងតំបន់នេះ ដែលចាប់ផ្តើមដំណាក់កាលទី ២ នៃកម្មវិធី UN-REDD ចំណែកឆ្នាំ ២០១២ គម្រោងនៅឧត្តរមានជ័យក្នុងប្រទេសកម្ពុជា បានក្លាយជាគម្រោងដំបូងក្នុងតំបន់នេះ ដែលសម្រេចបាននូវការផ្តល់សុពលភាពតាមស្តង់ដារកាបូនដែលអាចផ្ទៀងផ្ទាត់បាន(VCS) និងស្តង់ដារអាកាសធាតុសហគមន៍និងជីវៈចម្រុះ(CCB)។ ក្នុងបរិបទនេះ ការបង្កើតយន្តការនានាសម្រាប់ការទទួល គ្រប់គ្រង និងផ្ទេរមូលនិធិពីគម្រោងរេដបូក បានទទួលចំណាប់អារម្មណ៍ជាច្រើន។

ឯកសារនេះផ្តោតការយកចិត្តទុកដាក់លើការវិភាគប្រៀបធៀបទិដ្ឋភាពនានានៃប្រតិបត្តិការរេដបូក ឬមូលនិធិព្រៃឈើ។ ទម្លាប់ល្អនិងមេរៀនទទួលបាន ត្រូវបានស្រង់យកពីមូលនិធិដែលមានស្រាប់ចំនួនប្រាំបីដែលតំណាងឲ្យភាពចម្រុះនៃមូលនិធិរេដបូកនៅថ្នាក់ជាតិនិងថ្នាក់តំបន់ មូលនិធិប្រែប្រួលអាកាសធាតុ និងមូលនិធិការពារព្រៃឈើ។ មូលនិធិទាំងនេះត្រូវបានជ្រើសយក ដើម្បីផ្តល់ព័ត៌មានអំពីទម្រង់រួម និងបទប្បញ្ញត្តិសមស្រប សម្រាប់ស្ថាប័នមូលនិធិនៅថ្នាក់ជាតិដែលទទួលហិរញ្ញវត្ថុពីប្រភពអន្តរជាតិ និងដែលកំពុងប្រតិបត្តិការក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មេរៀនដែលទទួលបានពីមូលនិធិបន្សាំនៅក្រោម UNFCCC អំពីលក្ខខណ្ឌសម្រាប់មូលនិធិជាតិ ក៏បានទទួលការពិចារណាដោយត្រួសៗផងដែរ។ កិច្ចជានាលើការគ្រប់គ្រងជំនួសលើមូលនិធិ និងលក្ខខណ្ឌសម្រាប់វិស័យហិរញ្ញវត្ថុ ដែលមានឥទ្ធិពលមកលើការចរចានៅជុំវិញការបង់ថ្លៃទៅតាមលទ្ធផល ក៏ត្រូវបានពិនិត្យមើលផងដែរ ប៉ុន្តែមិនមានចែងពិស្តារឡើយ។

ឯកសារនេះត្រូវបានរៀបរៀងឡើងដូចតទៅ៖ ផ្នែកទី ១.២ បង្ហាញពីទិដ្ឋភាពរួមនៃតួនាទី និងមុខងាររបស់មូលនិធិរេដបូកនៅថ្នាក់ជាតិ ចំណែកផ្នែកទី២ ធ្វើការវិភាគប្រៀបធៀបមូលនិធិនានាដែលបានពិនិត្យ ដោយផ្តោតលើទិដ្ឋភាពនានាចំនួន៧ ដែលត្រូវបានរំពឹងថាជាស្នូលនៃការបង្កើតមូលនិធិរេដបូកនៅប្រទេសវៀតណាម។ នៅក្នុងករណីនីមួយៗ វិធីសាស្ត្រចំបងៗដែលយកមកប្រើប្រាស់សម្រាប់បញ្ហានីមួយៗ និងការពាក់ព័ន្ធសម្រាប់មូលនិធិនីមួយៗទាំងនោះ មានបង្ហាញក្នុងគោលដៅកំណត់អត្តសញ្ញាណមេរៀនអំពីការបង្កើតសមាសភាគនីមួយៗ។ ទិដ្ឋភាពរួមពិស្តារនៃមូលនិធិនីមួយៗ មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ ១។

## ១.២ តួនាទី និងមុខងាររបស់មូលនិធិរ៉េដបូក

សម្រាប់រ៉េដបូក ការបង់ថ្លៃទៅតាមលទ្ធផល អាចចាត់ចូលក្នុងជំពូកមួយនៃវិធីសាស្ត្រថ្មីៗ នៃការឈានទៅរកការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA) ដូចជា "បង់ប្រាក់នៅពេលប្រគល់លទ្ធផល" និង"ការបង់ថ្លៃទៅតាមលទ្ធផល" ដែលក្នុងនោះការបង់ថ្លៃ ត្រូវអនុវត្តទៅតាមលក្ខខណ្ឌដែលផ្អែកតាមលទ្ធផលជាក់លាក់។ នៅក្នុងករណីរ៉េដបូកបែបនេះ មានការរំពឹងថា លទ្ធផលដែលអាចទទួលបានជាការបង់ថ្លៃនឹងត្រូវវាស់ ដោយគិតជាកម្រិតនៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់(GHG) ធៀបនឹងកម្រិតបំភាយគោល។ លទ្ធផលបន្ថែមដទៃទៀតដូចជា លទ្ធផលដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ ការអភិរក្សទឹក និងលទ្ធផលខាងជីវៈចម្រុះ អាចបានទទួលរង្វាន់ហិរញ្ញវត្ថុ ទៅតាមករណីទាំងនេះ ទោះបីជាទូទៅ គេនៅពុំទាន់បានបង្កើតជារង្វាស់រួមពេញលេញក៏ដោយ។

អត្ថប្រយោជន៍មួយក្នុងចំណោមអត្ថប្រយោជន៍នានានៃការបង់ថ្លៃទៅតាមលទ្ធផលគឺថា អ្នកទទួលមាន**ភាពម្ចាស់ការ និងគណនេយ្យភាពពេញលេញក្នុងការសម្រេចលទ្ធផល** ដែលជាការដោះដូរនឹងការបង់ថ្លៃ ដែលពួកគេទទួលបាន។ ការឈានពីហិរញ្ញវត្ថុដែលផ្អែកលើកម្មវិធី ទៅរកហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល គឺជាការពង្រឹងអំណាចរបស់ស្ថាប័នជាតិ និងពង្រឹងអធិបតេយ្យ តាមរយៈការផ្ទេរសិទ្ធិសម្រេចខាងប្រតិបត្តិការទៅថ្នាក់ក្រោម។ វិធីនេះក៏ផ្តល់ឲ្យប្រទេសដែលជាអ្នកទទួលនូវឆន្ទានុសិទ្ធិច្រើនជាងមុនក្នុងការប្រើប្រាស់មូលនិធិទាំងនេះផងដែរ។

សម្រាប់រ៉េដបូក ចំណុចចាប់ផ្តើមនៃការគ្រប់គ្រង និងការចាត់ចែងរដ្ឋបាលលើការបង់ថ្លៃទៅតាមលទ្ធផល គឺការបង្កើត ឬការកំណត់អំពីមូលនិធិរ៉េដបូក។ មូលនិធិទាំងនេះគួរតែអនុញ្ញាតឲ្យមានការគ្រប់គ្រងវិភាគទានពីអន្តរជាតិតាមវិធីដែលធានា**តម្លាភាព ប្រសិទ្ធភាព និងភាពផ្តល់ផល**។ អាស្រ័យលើសមត្ថភាពរបស់ខ្លួន មូលនិធិទាំងនេះអាចមានលក្ខណៈប្រមូលផ្តុំ ឬ **វិមជ្ឈការ** ហើយការសម្រេចអាច**ផ្ទេរហិរញ្ញវត្ថុ**ទៅថ្នាក់ក្រោមបានតិច ឬ ច្រើន។

**ប្រអប់ ១៖ ស្តង់ដារនៃការធានាគ្រប់គ្រងមូលនិធិបន្សាំ**

**ស្តង់ដារនៃការធានាគ្រប់គ្រងសម្រាប់ NIE និងមូលនិធិបន្សាំ៖** នៅក្នុងការបង្កើតមូលនិធិបន្សាំ ភាគីនៅក្រោមពិធីសារក្យូតូបានសម្រេចថា មូលនិធិនេះត្រូវធ្វើ"ការគ្រប់គ្រងហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ ដែលរួមទាំងការប្រើប្រាស់ស្តង់ដារអន្តរជាតិសម្រាប់ការគ្រប់គ្រងមូលនិធិផងដែរ" (សេចក្តីសម្រេច 5/CMP.2)។ កិច្ចប្រជុំលើកទី៧នៃក្រុមប្រឹក្សាមូលនិធិបន្សាំ បានអនុម័តស្តង់ដារនៃការធានាលើការគ្រប់គ្រងដែលជាលក្ខខណ្ឌសម្រាប់អង្គភាពអនុវត្តមូលនិធិនេះ

ក) **ភាពពេញលេញ និងការគ្រប់គ្រងហិរញ្ញវត្ថុ**

- ការកត់ត្រាប្រតិបត្តិការ និងតុល្យការបានត្រឹមត្រូវ និងទៀងទាត់ ការធ្វើសវនកម្មតាមចន្លោះពេលទៀងទាត់ ដោយក្រុមហ៊ុនសវនកម្ម ឬអង្គការឯករាជ្យ។
- ការគ្រប់គ្រងនិងផ្ទេរមូលនិធិប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធសុវត្ថិភាព សម្រាប់អ្នកទទួល ទៅតាមពេលកំណត់
- ការកសាងផែនការ និងលើកថវិកា ដោយពិចារណាអំពីពេលខាងមុខ
- ស្ថានភាពចំពោះមុខច្បាប់ក្នុងការចុះកិច្ចសន្យាជាមួយមូលនិធិបន្សាំ និងភាគីទីបី។

ខ) **សមត្ថភាពស្ថាប័ន**

- នីតិវិធីលទ្ធកម្មដែលផ្តល់នូវទម្លាប់អនុវត្តល្អ ដែលរួមទាំង ភាពប្រកួតប្រជែងផងដែរ
- សមត្ថភាពដើម្បីអនុវត្តការងារពិនិត្យតាមដាន និងវាយតម្លៃ
- សមត្ថភាពក្នុងការកំណត់អត្តសញ្ញាណ បង្កើត និងវាយតម្លៃគម្រោង/កម្មវិធី
- សមត្ថភាពគ្រប់គ្រងឬចាត់ចែងការអនុវត្តគម្រោង/កម្មវិធី ដែលរួមទាំងសមត្ថភាពក្នុងការគ្រប់គ្រងក្រុមតូចៗដែលជាអ្នកទទួល និងគាំទ្រដល់ការអនុវត្ត និងការប្រគល់

**គ) តម្លាភាព និងអំណាចស៊ើបអង្កេតដោយខ្លួនឯង**

- សមត្ថភាពដោះស្រាយបញ្ហានៃការគ្រប់គ្រងហិរញ្ញវត្ថុមិនបានត្រឹមត្រូវ និងទម្រង់ដទៃនៃការអនុវត្តមិនត្រឹមត្រូវ។

**មូលនិធិបន្សាំ** ផ្តល់ជាមេរៀនដ៏មានប្រយោជន៍អំពីលក្ខខណ្ឌនានាដែលយកមកអនុវត្តជាមួយអង្គភាពដែលជាអ្នកទទួលនៅថ្នាក់ជាតិ ហើយលក្ខខណ្ឌប្រហាក់ប្រហែលគ្នានេះ អាចត្រូវដាក់ឲ្យអនុវត្តសម្រាប់មូលនិធិរេដបូកផងដែរ។ ប្រទេសនានាបានបង្កើតអង្គភាពអនុវត្តរបស់ជាតិ(NIEs)នៅក្រោមមូលនិធិបន្សាំ ហើយក្រោយបានការទទួលស្គាល់ពីក្រុមប្រឹក្សាមូលនិធិបន្សាំ(AFB) អង្គភាពនេះផ្តល់ការជានាគ្រប់គ្រងមូលនិធិ ទន្ទឹមនឹងអង្គភាពអនុវត្តពហុភាគីផងដែរ។ ដើម្បីធ្វើបែបនេះបាន NIEs ត្រូវគោរពតាមលក្ខណៈវិនិច្ឆ័យនៃការជានាគ្រប់គ្រង ដែលបានបង្កើត និងបានការអនុម័តពីក្រុមប្រឹក្សាមូលនិធិ(សូមអានប្រអប់ ១)។ នៅក្រោមរេដបូក អង្គភាពផ្តល់មូលនិធិជាតិ ទំនងជាទទួល តួនាទីកាន់តែលេចធ្លោជាងនៅក្រោមមូលនិធិបន្សាំ បើទោះបីម្ចាស់ជំនួយទំនងជារំពឹងចង់ឲ្យមានលក្ខណៈវិនិច្ឆ័យនៃការជានាប្រហាក់ប្រហែលគ្នាសម្រាប់ការទទួលស្គាល់ពី AFB ក៏ដោយ។

ដើម្បីបំពេញបានតាមលក្ខណៈវិនិច្ឆ័យទាំងនេះ មូលនិធិរេដបូកនៅថ្នាក់ជាតិត្រូវតែ ១) មានឯករាជ្យភាពដាច់ចេញពីរដ្ឋាភិបាល ទៅតាមកម្រិតដែលអាចធ្វើបាន ២) គ្រប់គ្រងដោយអង្គភាពឯករាជ្យ/ក្រុមអ្នកគ្រប់គ្រងឯករាជ្យ ៣) អនុវត្តស្តង់ដារគណនេយ្យអន្តរជាតិ និងគោរពតាមលក្ខណៈវិនិច្ឆ័យនៃការជានាគ្រប់គ្រងជាអន្តរជាតិ និង ៤)គ្រប់គ្រងតាមទម្រង់ដែលមានតម្លាភាព។

ការបង្កើតមូលនិធិរេដបូកជាតិ អាចខុសគ្នាអាស្រ័យលើប្រព័ន្ធសេដ្ឋកិច្ច និងច្បាប់ដែលមានស្រាប់ គោលនយោបាយ និងក្របខ័ណ្ឌស្ថាប័នក្នុងប្រទេស និងវត្តមានធនធាន។ ទោះជាយ៉ាងណាក៏ដោយ មូលនិធិរេដបូកជាតិ ត្រូវអនុវត្តមុខងារសំខាន់ៗមួយចំនួន៖

១) គ្រប់គ្រងទំនាក់ទំនងជាមួយអង្គភាពនានាដែលប្រតិបត្តិការនៅក្រោម (ក)យន្តការរេដបូកនៃ UNFCCCC (ខ) កម្មវិធីរេដបូកនៅថ្នាក់ជាតិ ឬថ្នាក់តំបន់ និង (គ) ប្រភពមូលនិធិរេដបូកនៅថ្នាក់ជាតិ និងទ្វេភាគី។ ទំនាក់ទំនងទាំងនោះរួមមាន៖[1]

ក. លើកស្នើ និងទទួលមូលនិធិពីប្រភពអន្តរជាតិ

ខ. ដាក់ជូនយុទ្ធសាស្ត្ររេដបូករបស់ប្រទេស

គ. ដាក់ជូនរបាយការណ៍រេដបូករបស់ ប្រទេស ដោយមានបង្ហាញពីគុណផលនៃ MRV និង

ឃ. ធ្វើរបាយការណ៍ជាទៀងទាត់ទៅ COP ឬ អង្គភាពថ្នាក់ខ្ពស់ជាងនេះ អំពីការអនុវត្តរេដបូក។

២. ឯកភាពចំពោះ និងអនុវត្ត៖

ក. ការផ្តល់មូលនិធិអន្តរជាតិ ការជានា និងនីតិវិធីរាយការណ៍

ខ. ស្តង់ដារ វិធីសាស្ត្រ MRV និងនីតិវិធីបច្ចេកទេសដទៃទៀត

គ. ស្តង់ដារសង្គម និងបរិស្ថាន និងនីតិវិធីបណ្តឹងទាសំណងជម្ងឺចិត្ត

ឃ. គ្រប់គ្រងលើទំនាក់ទំនងជាមួយទីផ្សារកាបូនអន្តរជាតិ។

សមត្ថភាពរបស់មូលនិធិរេដបូក គឺជាកត្តាកំណត់អំពីការទទួលខុសត្រូវ ដែលភ្នាក់ងារអន្តរជាតិផ្ទេរទៅឲ្យស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មូលនិធិរេដបូកអន្តរជាតិដែលបច្ចុប្បន្នមានទំហំតូច និងចំនួនតិច នឹងមានតួនាទីជាឧបសគ្គចំពោះការអភិវឌ្ឍរចនាសម្ព័ន្ធហិរញ្ញប្បទានរេដបូកសម្រាប់រយៈពេលវែង។ រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត

[1] Streck, C. et al. REDD+ Institutional Options Report. Meridian Institute (p. 23). 2009. Available from: http://www.redd-oar.org/links/REDD+IOA_en.pdf.

មានតួនាទីនាំមុខ ក្នុងការបង្កើតរចនាសម្ព័ន្ធមូលនិធិជាតិ និងយុត្តាធិការ ហើយការពិនិត្យឡើងវិញនេះមានគោលដៅផ្តល់ជាវិភាគទានទៅក្នុងកិច្ចប្រឹងប្រែងបែបនេះ។

# ២. ការប្រៀបធៀបបទពិសោធន៍ជាមួយមូលនិធិអន្តរជាតិ

ផ្នែកនានាខាងក្រោមនេះពិនិត្យមើលមូលនិធិចំនួនប្រាំបី ដែលបង្ហាញពីគោលដៅខុសៗគ្នា ដោយរាប់ចាប់ពីការផ្តល់មូលនិធិសម្រាប់តំបន់ការពារធម្មជាតិ រហូតដល់ការទទួល គ្រប់គ្រង និងផ្ទេរមូលនិធិរ៉េដបូកទៅតាមគុណផលផងដែរ។ តារាង ១ បង្ហាញពីទិដ្ឋភាពរួមនៃមូលនិធិនីមួយៗដែលបានពិនិត្យ។ ការប្រៀបធៀបត្រូវបានធ្វើឡើង តាមរយៈការពិនិត្យមើលឯកសារដើមរបស់មូលនិធិទាំងនេះ និងឯកសារបន្ទាប់បន្សំ ដែលរួមទាំង ច្បាប់ដែលចែងអំពីការបង្កើតមូលនិធិទាំងនោះ អនុស្សារណៈនៃការយោគយល់ ឯកសារគោលគំនិត នីតិវិធីអនុវត្ត គោលការណ៍ណែនាំអំពីលទ្ធកម្ម និងឯកសារដទៃទៀត ឬ ក្របខ័ណ្ឌណែនាំ ដែលអធិប្បាយអំពីការបង្កើតមូលនិធិ រចនាសម្ព័ន្ធ និងការគ្រប់គ្រង។ ការវិភាគបានផ្តោតលើសមាសភាគជាក់លាក់ចំនួន ៧ ដែលមានសារៈសំខាន់ជាស្នូល ចំពោះការគ្រប់គ្រងមូលនិធិឲ្យមានប្រសិទ្ធភាព និងដែលផ្តល់ផលដូចតទៅ៖

(១) រចនាសម្ព័ន្ធមូលនិធិ - ផ្សំដោយរចនាសម្ព័ន្ធទូទៅនៃមូលនិធិ ដែលរួមទាំង ភាពជានីតិបុគ្គល និងទំនាក់ទំនងជាមួយរដ្ឋាភិបាល ការបង្កើតយន្តការ មូលនិធិជាច្រើនបែប និងប្រភពនៃការផ្តល់មូលនិធិដែលមានប្រើប្រាស់

(២) អភិបាលកិច្ចនិងការគ្រប់គ្រងមូលនិធិ - ប្រភេទស្ថាប័នដែលទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងមូលនិធិ រួមទាំងសមាសភាព មុខងារ និងការទទួលខុសត្រូវរបស់ខ្លួន

(៣) គោលការណ៍ និងបទបញ្ជាលើការវិនិយោគ - វិធាន បទបញ្ជា និងគោលការណ៍ណែនាំ ដែលមានចែងអំពីការវិនិយោគធនធានពីមូលនិធិនេះ

(៤) លក្ខណៈវិនិច្ឆ័យអំពីភាពទទួលយកបាននិងការជ្រើសរើស - ប្រភេទសកម្មភាពនិងអង្គភាពដែលមានលក្ខណៈសមស្របសម្រាប់ការផ្តល់មូលនិធិ ក៏ដូចជា លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសអ្នកទទួលផងដែរ

(៥) ការវាយតម្លៃ និង MRV - គោលការណ៍ និងដំណើរការសម្រាប់ការពិនិត្យតាមដាននិងវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងតម្លាភាពលើ (១)គុណផលជារួមនៃមូលនិធិ និង (២)គុណផលនៃសកម្មភាពនីមួយៗដែលបានទទួលមូលនិធិគាំទ្រ

(៦) ប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថាន - បទបញ្ជា និងគោលការណ៍ណែនាំនានាដែលធានាថា ការប្រើប្រាស់មូលនិធិមានភាពស្របគ្នាជាមួយគោលដៅសង្គមនិងបរិស្ថាន និងមិននាំមកនូវផលប៉ះពាល់អវិជ្ជមានឡើយ និង

(៧) លក្ខខណ្ឌជាក់លាក់កំណត់ដោយម្ចាស់ជំនួយ - តម្រូវការដែលបានបង្កើតឡើងដោយម្ចាស់ជំនួយនៃមូលនិធិនេះ ជាលក្ខខណ្ឌសម្រាប់ផ្តល់ហិរញ្ញវត្ថុទៅក្នុងមូលនិធិនោះ ។

តារាង ១៖ ទិដ្ឋភាពរួមសំខាន់ៗនៃមូលនិធិដែលបានពិនិត្យ

| | គោលដៅនៃការផ្តល់មូលនិធិ | អភិបាលកិច្ច | ការវិនិយោគ | លក្ខណៈវិនិច្ឆ័យជ្រើសរើស | MRV | ប្រព័ន្ធសុវត្ថិភាព | លក្ខខណ្ឌដាក់លាក់របស់ម្ចាស់ជំនួយ |
|---|---|---|---|---|---|---|---|
| **មូលនិធិវិនិយោគ រេដបូកនៅហ្គុយយ៉ាណា** (GRIF) | រេដបូក | ធនាគារពិភពលោកគ្រប់គ្រងមូលនិធិត្រាស់, អនុវត្តទៅតាមក្រុមប្រឹក្សាដឹកនាំដែលមានសមាសភាពមកពីរដ្ឋាភិបាល-ម្ចាស់ជំនួយ | មាន, ក្របខ័ណ្ឌកម្រិតអប្បបរមា និងហិរញ្ញវត្ថុដែលងាយដោះដូរបាន | ផ្អែកលើLCDs របស់ហ្គុយយ៉ាណា | ផ្អែកលើគុណផល (កម្រិតមូលនិធិ) សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ | យោងតាមគោលនយោបាយរបស់ធនាគារពិភពលោកនិងអង្គភាពអនុវត្ត | សូចនាករសមត្ថភាពត្រូវបានដាក់បញ្ចូលស្របជាមួយសូចនាករគុណផល |
| **មូលនិធិព្រៃឈើអាងកុងហ្គោ** (CBFF) | រេដបូក | AfDB គ្រប់គ្រងមូលនិធិត្រាស់ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលពហុអ្នកពាក់ព័ន្ធនិងគាំទ្រដោយភ្នាក់ងារគ្រប់គ្រងមូលនិធិឯកជន | មាន, ការវិនិយោគទៅតាមការសម្រេចរបស់អ្នកគ្រប់គ្រង | ផ្អែកលើការបន្ស៊ី ជាមួយលក្ខណៈវិនិច្ឆ័យចំនួន៦ | សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ( ទាំងនៅកម្រិតមូលនិធិ និងកម្រិតគម្រោង ) | យោងតាមគោលនយោបាយរបស់ AfDB | ប្រើប្រាស់មូលនិធិប្រយុទ្ធប្រឆាំងការបាត់បង់ព្រៃឈើ បង្កើតលក្ខខណ្ឌគោលរបស់ជាតិ និងប្រព័ន្ធ MRV និងពង្រឹងភាពជាដៃគូរដ្ឋាភិបាល/សង្គមស៊ីវិល |
| **មូលនិធិអាម៉ាហ្សូន** | រេដបូក | ធនាគារជាតិគ្រប់គ្រងមូលនិធិត្រាស់ ដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលពហុអ្នកពាក់ព័ន្ធនិងគាំទ្រដោយគណៈកម្មាធិការ | មាន, មូលនិធិងាយដោះដូរបាន ត្រូវបានយកទៅវិនិយោគដែលផ្តល់ចំណូលទៀងទាត់ | គម្រោងត្រូវតែកាត់បន្ថយការបាត់បង់ព្រៃឈើដោយផ្ទាល់ ឬប្រយោល ដោយរហូតដល់២០%ត្រូវបានបម្រុងទុកដោយឡែកសម្រាប់គម្រោង | ផ្អែកលើគុណផល (កម្រិតមូលនិធិ), សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ | SES រេដបូក និងអនុលោមតាមគោលនយោបាយ BNDES | មិនច្បាស់លាស់ |

| | គោលដៅនៃការផ្តល់មូលនិធិ | អភិបាលកិច្ច | ការវិនិយោគ | លក្ខណៈវិនិច្ឆ័យជ្រើសរើស | MRV | ប្រព័ន្ធសុវត្ថិភាព | លក្ខខណ្ឌដាក់លាក់របស់ម្ចាស់ជំនួយ |
|---|---|---|---|---|---|---|---|
| | | បច្ចេកទេស | | អន្តរជាតិនិងគម្រោងនៅខាងក្រៅឬូមអាម៉ាហ្សូន | | | |
| **មូលនិធិត្រាស់ប្រែប្រួលអាកាសធាតុឥណ្ឌូនេស៊ី** (ICCTF) | វិស័យកាត់បន្ថយការប្រែប្រួលអាកាសធាតុទាំងអស់ | រដ្ឋាភិបាលមានសមាសភាពច្រើនលើសលុបក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចដោយមាន UNDP ដើរតួជាអ្នកគ្រប់គ្រង | គ្មាន | គម្រោងគាំទ្រដោយក្រសួងពាក់ព័ន្ធដែលមានផែនការសកម្មភាពជាតិកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ | សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ | យោងតាមគោលនយោបាយរបស់ UNDP | មិនច្បាស់លាស់ |
| **មូលនិធិព្រៃឈើ ម៉ិកស៊ិក** | សកម្មភាពព្រៃឈើជាច្រើនបែប | ធនាគារជាតិគ្រប់គ្រង, ដឹកនាំដោយក្រុមប្រឹក្សាភិបាលពហុអ្នកពាក់ព័ន្ធ | មាន, ការវិនិយោគរយៈពេលវែងត្រូវបានបង្កើន | អាស្រ័យលើកម្មវិធីរង | សវនកម្មជារួមដោយសវនករសហព័ន្ធ, កម្រិតអ្នកទទួលអាស្រ័យលើកម្មវិធី | គ្មានទិន្នន័យ | ភាគច្រើនទទួលមូលនិធិពីក្នុងប្រទេស, ការចូលរួមទៅអនាគតនៅក្នុង FIP នឹងទាក់ទងជាមួយការប្រើនីតិវិធីរបស់ធនាគារពិភពលោក |
| **មូលនិធិប៉េរូសម្រាប់ឧទ្យានជាតិនិងតំបន់ការពារធម្មជាតិ** (PROFONANPE) | អភិរក្សនិងគ្រប់គ្រងតំបន់ការពារធម្មជាតិ | អង្គភាពស្របច្បាប់ឯករាជ្យ ដឹកនាំដោយក្រុមប្រឹក្សាភិបាលពហុអ្នកពាក់ព័ន្ធ | មាន, គ្របខ័ណ្ឌវិនិយោគអប្បបរមាដែល គ្រប់គ្រងដោយផ្នែកឯកជន | គម្រោងនីមួយៗត្រូវទទួលមូលនិធិពីម្ចាស់ជំនួយដោយឡែកពីគ្នា | ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យគ្រប់គម្រោង, សវនកម្មឯករាជ្យគ្រប់គម្រោង | ប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពរបស់ធនាគារពិភពលោក | ជំនួយឥតសំណងត្រូវមានកិច្ចព្រមព្រៀង |
| **មូលនិធិហិរញ្ញប្បទានព្រៃឈើជាតិកូស្តារីកា** (FONAFIFO) | អភិរក្សដោយម្ចាស់ព្រៃខ្នាតតូចនិងមធ្យម | អង្គភាពពាក់កណ្ដាលរដ្ឋ ដឹកនាំដោយក្រុមប្រឹក្សាភិបាលនៃអ្នកពាក់ព័ន្ធសាធារណៈ-ឯកជននិងមាន | គ្មានទិន្នន័យ | អាស្រ័យលើកម្មវិធីរង, ចាត់លំដាប់អ្នកចូលរួមទៅតាមគុណតម្លៃអេកូឡូស៊ីនៃដែនដី | អង្គភាពឯកជនទទួលខុសត្រូវធ្វើសវនកម្មរបាយការណ៍របស់អ្នកចូលរួម, សវនកម្មឯករាជ្យ | គោលនយោបាយសង្គមនិងបរិស្ថានបណ្តោះអាសន្ន ប្រើប្រាស់ក្នុងមូលនិធិពីក្នុងប្រទេស, ស្តង់ដារ | ចរន្តនៃការផ្តល់មូលនិធិខ្លះត្រូវជាប់លក្ខខណ្ឌដោយឡែករបស់ម្ចាស់ជំនួយ |

| | គោលដៅនៃការផ្តល់មូលនិធិ | អភិបាលកិច្ច | ការវិនិយោគ | លក្ខណៈវិនិច្ឆ័យជ្រើសរើស | MRV | ប្រព័ន្ធសុវត្ថិភាព | លក្ខខណ្ឌដាក់លាក់របស់ម្ចាស់ជំនួយ |
|---|---|---|---|---|---|---|---|
| | | អ្នកគ្រប់គ្រងនៅថ្នាក់ជាតិ | | | ប្រចាំឆ្នាំ | ម្ចាស់ជំនួយប្រើប្រាស់ក្នុងមូលនិធិដែលទទួលពីម្ចាស់ជំនួយ | |
| **មូលនិធិការពារបរិស្ថានឡាវ** (EPF) | គម្រោងការពារបរិស្ថាន | អង្គភាពស្វយ័តដែលដឹកនាំដោយក្រុមប្រឹក្សាភិបាលពហុភាគី | មាន, ការផ្តល់មូលដំបូងដែលវិនិយោគលើមូលនិធិទាយជ្ជទាន | ការវាយតម្លៃទៅតាមករណីដាច់ពីគ្នា | អង្គភាពគ្រប់គ្រងធ្វើការពិនិត្យគុណផលជារួម, នីតិវិធីងាយៗសម្រាប់គម្រោងតូចៗ | ប្រព័ន្ធសុវត្ថិភាពផ្ទៃក្នុងផ្អែកតាមប្រព័ន្ធសុវត្ថិភាពរបស់ធនាគារពិភពលោក | មូលនិធិហិរញ្ញប្បទានម្ចាស់ជំនួយនីមួយៗអាចស្នើឲ្យគោរពតាមគោលនយោបាយ/ស្តង់ដាររបស់ខ្លួនជំនួសឲ្យគោលនយោបាយស្តង់ដារ |

## ២.១ រចនាសម្ព័ន្ធមូលនិធិ

**ចំណុចគន្លឹះ:**

- មូលនិធិភាគច្រើន គឺជាមូលនិធិឯករាជ្យ និងដាច់ដោយឡែក បើទោះជាមូលនិធិជាច្រើនមានមូលនិធិរង ឬយន្តការសម្រាប់ការផ្តល់មូលនិធិទៅតាមផ្នែកខុសៗគ្នាក៏ដោយ
- មូលនិធិដែលមានជោគជ័យជាងគេបានធានាឲ្យមានចរន្តនៃការផ្តល់មូលនិធិច្រើនបែប
- ការបង្កើនពិពិធកម្មប្រភពមូលនិធិ និងធ្វើឲ្យវិស័យឯកជនចូលរួម តាមរយៈការកំណត់ឲ្យបង់ថ្លៃ ឬ តាមការស្ម័គ្រចិត្ត អាចបង្កើនមូលនិធិ និងកំហិតការប្រឈមចំពោះបញ្ហានយោបាយ ឬ សេដ្ឋកិច្ច។

មូលនិធិភាគច្រើនដែលបានអង្កេត ដែលរួមទាំង មូលនិធិរ៉េដបូក មានលក្ខណៈជាមូលនិធិ**ឯករាជ្យ និងស្ថិតនៅដាច់តែឯង** តែមិនមែនជាសមាសភាគនៃមូលនិធិផ្សេងទៀតឡើយ។ ទោះជាយ៉ាងណាក៏ដោយ មូលនិធិទាំងនេះជាច្រើនផ្សំដោយមូលនិធិរងមួយចំនួន ដែលទាក់ទងនឹងបញ្ហាតាមផ្នែកខុសៗគ្នា (ដូចជា FONAFIA នៅប្រទេសកូស្តារីកា) ឬទាក់ទងនឹងគម្រោងខ្នាតធំជាក់លាក់ (ដូចជា PROFONANPE នៃប្រទេសប៉េរូ)។ មូលនិធិនានា ក៏បានប្រើប្រាស់**ប្រភេទមូលនិធិខុសៗគ្នា** ដើម្បីឆ្លើយតបនឹងគោលដៅខុសៗគ្នាផងដែរ។ ឧទា. PROFONANPE ប្រើប្រាស់បង្គុំមួយនៃទាយជ្ជទាន ពោលគឺមូលនិធិសម្រាប់វិនិយោគទៅអនាគត(sinking fund) និងមូលនិធិចម្រុះ។ មូលនិធិទាយជ្ជទានត្រូវបានប្រើប្រាស់សម្រាប់គម្រោងនានាដែលមានដើមទុនច្រើនបង្គួរ និងទាមទារឲ្យមានស្ថិរភាពហិរញ្ញវត្ថុសម្រាប់រយៈពេលវែង។ មូលនិធិសម្រាប់វិនិយោគទៅអនាគត ត្រូវបានប្រើប្រាស់សម្រាប់គម្រោងនានា ដែលទាមទារឲ្យមានហិរញ្ញវត្ថុដែលងាយដោះដូរបានក្នុងបរិមាណយ៉ាងច្រើន។ មូលនិធិចម្រុះត្រូវបានប្រើប្រាស់សម្រាប់គម្រោងនានា ដែលទាមទារឲ្យមានតុល្យភាពរវាងស្ថិរភាពរយៈពេលវែង និងភាពដោះដូរបានក្នុងរយៈពេលខ្លី។

ទាក់ទងនឹងប្រភពនៃការផ្តល់ហិរញ្ញវត្ថុ មូលនិធិដែលទទួលជោគជ័យជាងគេនៅក្នុងការពិនិត្យនេះ ស្ថិតក្រោមការគ្រប់គ្រងក្នុងគោលដៅធានាឲ្យមាន**ការផ្តល់មូលនិធិពីប្រភពជាច្រើន** ដែលជួយពួកគេក្នុងការទប់ទល់នឹងឥទ្ធិពលជាក់លាក់ខាងនយោបាយ ឬសេដ្ឋកិច្ច។ មូលនិធិរ៉េដបូក និងមូលនិធិអាកាសធាតុជាតិ ដែលបានពិនិត្យមកទល់ពេលនេះ បានពឹងផ្អែកជាបឋមលើម្ចាស់ជំនួយអន្តរជាតិពីវិស័យសាធារណៈ ជាពិសេស ពីប្រទេសន័រវេស អាល្លឺមង់ និងចក្រភពអង់គ្លេស បើទោះជាមូលនិធិអាម៉ាហ្សូន បានទទួលបរិមាណត្រឹមតិចតួច (៤,២លានដុល្លាអាមេរិក)ពីក្រុមហ៊ុនប្រេងកាតជាតិក៏ដោយ ពោលគឺ ប៉េត្រូប្រាស (Petrobras)។

ម្យ៉ាងវិញទៀត មូលនិធិព្រៃឈើដែលមានអាយុចំណាស់មួយចំនួនបានទទួល**ហិរញ្ញប្បទានក្រាស់ក្រែលពីវិស័យឯកជនជាតិ** ជាពិសេសតាមរយៈការតម្រូវឲ្យបង់ពន្ធ និងអាករនានា ហើយនៅក្នុងមូលនិធិ FFM និង FONAFIFO នេះគឺជាប្រភពចំបងនៃមូលនិធិដែលពួកគេបានទទួល។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ផងដែរថា មូលនិធិទាំងពីរនេះបានផ្តោតជាខ្លាំងលើការបង់ថ្លៃសម្រាប់សេវាបរិស្ថាន ដែលផ្តល់ចំណងទាក់ទងច្បាស់លាស់ជាមួយការបង់ថ្លៃរបស់វិស័យឯកជន។ ការបង់ថ្លៃដោយស្ម័គ្រចិត្តពីអង្គភាពនានាក្នុងវិស័យឯកជនដែលប្រតិបត្តិការនៅក្នុងប្រទេស ក៏បានបង្កើតឡើងនៅក្នុងមូលនិធិមួយចំនួនផងដែរ តាមធម្មតាដោយផ្អែកលើការជម្រុញឲ្យមានភាពទទួលខុសត្រូវសង្គមនៃសារជីវកម្ម។ ក្នុងករណីទាំងអស់ ចំណូលបានពីផ្នែកនេះមានសមាមាត្រតិចតួចប៉ុន្តែវាផ្តល់ជាការបំពេញបន្ថែមដ៏មានប្រយោជន៍

ដល់ប្រភពហិរញ្ញវត្ថុដទៃទៀត។ នៅក្នុងករណីនៃមូលនិធិ FONAFIFO វិភាគទានបែបនេះត្រូវបានសម្របសម្រួលតាមរយៈការចេញវិញ្ញាបនប័ត្រសេវាកម្មបរិស្ថាន (ESCs) ដែលជាភស្តុតាងនៃការទទួលស្គាល់នូវវិភាគទាននេះ។

## ២.២ អភិបាលកិច្ច និងការគ្រប់គ្រងមូលនិធិ

**ចំណុចគន្លឹះ:**

- ការធានាឲ្យមានតុល្យភាពរវាងឯករាជ្យភាពខាងប្រតិបត្តិការ និងខាងផ្លូវច្បាប់នៃមូលនិធិ ដាច់ចេញពីរដ្ឋាភិបាល និងរក្សាបាននូវស្ថិរភាពដែលរដ្ឋាភិបាលមានភាពម្ចាស់ការ ត្រូវបានមើលឃើញថាជាកត្តាសំខាន់មួយក្នុងការទាក់ទាញហិរញ្ញវត្ថុពីម្ចាស់ជំនួយ
- មូលនិធិទាំងអស់មានទម្រង់ខ្លះៗនៃក្រុមប្រឹក្សាភិបាល និងអង្គភាពគ្រប់គ្រង ចំណែកមូលនិធិខ្លះទៀតក៏ប្រើប្រាស់យន្តការត្រាស់(គ្រប់គ្រងជំនួស) (trust facilities) គណៈកម្មាធិការបច្ចេកទេស ឬ អង្គភាពវិជ្ជាជីវៈក្នុងវិស័យឯកជនផងដែរ ដើម្បីបង្កើនប្រសិទ្ធភាព។ អង្គភាពក្នុងរដ្ឋាភិបាលអាចគាំទ្រ ប៉ុន្តែមិនដើរតួស្នូលណាមួយឡើយ
- ការរួមបញ្ចូលតុល្យភាពនៃតំណាងពីរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជននៅក្នុងក្រុមប្រឹក្សាភិបាលនិងការធានាឲ្យមានសិទ្ធិស្មើគ្នានៃតំណាងម្នាក់ៗ នៅក្នុងការបោះឆ្នោត បានបង្កើនភាពស្របច្បាប់ និងប្រសិទ្ធភាពនៃមូលនិធិ
- ការកំហិតលើថ្លៃចំណាយអន្តរការ បង្កើនភាពទាក់ទាញនៃមូលនិធិពីសំណាក់ម្ចាស់ជំនួយ។ ក្នុងករណីដែលទីភ្នាក់ងារអន្តរជាតិធំៗភាគច្រើនយកកម្រៃពី ១០-២០% ភស្តុតាងពីវិស័យឯកជន និងធនាគារជាតិបានបង្ហាញថា កម្រៃបែបនេះអាចបញ្ចុះមកត្រឹមតែ ៣%
- ការធានាឲ្យមានការទទួលខុសត្រូវគឺជាគន្លឹះ។ កាតព្វកិច្ចលើការធានាគ្រប់គ្រង នឹងជាប់ពាក់ព័ន្ធយ៉ាងហោចណាស់ជាមួយអ្នកគ្រប់គ្រង ប៉ុន្តែនៅក្នុងករណីជាច្រើន ក៏ទាក់ទងជាមួយអង្គភាពគ្រប់គ្រង ឬ បុគ្គលដទៃទៀត ដែលគ្រប់គ្រង ឬ ផ្ទេរមូលនិធិផងដែរ។

មូលនិធិភាគច្រើនដែលបានអង្កេត ដំណើរការជាអង្គភាពស្វយ័ត ឬ ពាក់កណ្តាលស្វយ័ត ដោយមាន**ឯករាជ្យភាពយ៉ាងច្រើនទាំងខាងផ្លូវច្បាប់ និងប្រតិបត្តិការដាច់ចេញពីរដ្ឋាភិបាល។** នៅក្នុងករណីភាគច្រើន ចំណុចនេះទាក់ទងនឹងមូលនិធិដែលមានឯករាជ្យភាពជានីតិបុគ្គល ដែលអាចជាអង្គភាពមិនស្វែងរកផលចំណេញក្នុងវិស័យឯកជន អង្គភាពគ្រប់គ្រងជំនួស ឬ អង្គភាពវិមជ្ឈការ ឬ ពាក់កណ្តាលចំណុះរដ្ឋ។ ទម្រង់ជាក់លាក់នៃនីតិបុគ្គលបែបនេះ អាស្រ័យភាគច្រើនទៅតាមបរិបទរបស់ជាតិ។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃឯករាជ្យភាពដាច់ចេញពីរដ្ឋាភិបាលបែបនេះ មានចំណងទាក់ទងជិតស្និទ្ធទៅនឹងប្រសិទ្ធភាពនៃមូលនិធិ និងសំខាន់ជាងនេះទៀតគឺ សមត្ថភាពក្នុងការទាក់ទាញហិរញ្ញវត្ថុពីម្ចាស់ជំនួយ។ ទន្ទឹមនឹងនេះ ប្រការសំខាន់គឺថា រដ្ឋាភិបាលមានភាពម្ចាស់ការរឹងមាំលើមូលនិធិ ដើម្បីធានាឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយ និងកម្មវិធីជាតិ។ ក្នុងករណីភាគច្រើន ចំណុចនេះអាចធ្វើបានតាមរយៈ ការផ្តល់តំណាងឲ្យបានទូលំទូលាយពីខាងរដ្ឋាភិបាល នៅក្នុងក្រុមប្រឹក្សាភិបាល (សូមអានខាងក្រោម) ឬ តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងអង្គភាពគ្រប់គ្រងមូលនិធិ និងអង្គភាពនានានៃរដ្ឋាភិបាល។ បទពិសោធន៍ពី PROFANANPE ក៏

បានគូសបញ្ជាក់ផងដែរថា ការរក្សាទុកមូលនិធិឲ្យមានឯករាជ្យភាពតាមផ្លូវច្បាប់ដាច់ចេញពីរដ្ឋាភិបាល អាចធានាថា ឥណទាយករបស់រដ្ឋ មិនអាចប្រើប្រាស់ធនធាននៅក្នុងមូលនិធិនេះដើម្បីទូទាត់បំណុលរបស់រដ្ឋាភិបាលឡើយ។

ទោះបីមូលនិធិដែលស្ថិតក្នុងការសិក្សានេះ មានភាពខុសគ្នាតាមរូបភាពជាច្រើនក៏ដោយ បើគិតពីរចនាសម្ព័ន្ធអភិបាលកិច្ចផ្ទៃក្នុង នៅក្នុងគ្រប់ករណីទាំងអស់ មានស្ថាប័នពីរបែបខុសគ្នាជាសំខាន់៖ ក្រុមប្រឹក្សាភិបាលមួយ (ដូចជា ក្រុមប្រឹក្សាដឹកនាំ ក្រុមប្រឹក្សានាយក) និងអង្គភាពគ្រប់គ្រង (ដូចជា ការិយាល័យប្រតិបត្តិ)។

ក្រុមប្រឹក្សាមានភារៈទទួលខុសត្រូវផ្តល់ការណែនាំជារួមអំពី ទិសដៅ និងការត្រួតពិនិត្យលើមូលនិធិ ដូចជាការបង្កើតនីតិវិធីប្រតិបត្តិការ និងការវិនិយោគ ចំណែកអង្គភាពគ្រប់គ្រងតាមធម្មតាគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃនៃមូលនិធិ និងនៅក្នុងករណីជាច្រើន អនុវត្តការទទួលខុសត្រូវក្នុងកម្រិតណាមួយលើការធានាខាងការគ្រប់គ្រងមូលនិធិ។ មូលនិធិមួយចំនួន ដូចជា GRIF និង ICCTF រួមបញ្ចូលតួនាទី និងការទទួលខុសត្រូវលើអ្នកអនុវត្តគម្រោង នៅក្នុងរចនាសម្ព័ន្ធចាត់ចែងទាំងមូលរបស់ខ្លួនថែមទៀតផង។

នៅក្នុងករណីភាគច្រើន **សមាជិកភាពនៃក្រុមប្រឹក្សាភិបាល**មានសមាសភាពជាតំណាងជាន់ខ្ពស់មកពីវិស័យសាធារណៈ(ដែលជាញឹកញាប់មកពីក្រសួង/ស្ថាប័នជាច្រើន) វិស័យឯកជន និងសង្គមស៊ីវិល។ នៅក្នុងមូលនិធិរ៉េដបូកមួយចំនួន ជាពិសេស GRIF និង ICCTF សង្គមស៊ីវិល និងតំណាងវិស័យឯកជនបានទទួលសិទ្ធិជាអ្នកសង្កេតការណ៍។ ទោះជាយ៉ាងណាក៏ដោយ នេះជាប្រការដែលស្ថិតក្រោមការទិទៀនជាច្រើន និងត្រូវបានចាត់ទុកថា បានរារាំងសមត្ថភាពរបស់មូលនិធិក្នុងការទាក់ទាញម្ចាស់ជំនួយជាច្រើន។ ដូចគ្នានេះដែរ ការពិនិត្យមើលរបស់មូលនិធិបរិស្ថានពិភពលោកលើមូលនិធិ PROFONANPE បានរកឃើញថា វត្តមានច្រើនលើសលប់របស់សមាសភាពពីរដ្ឋាភិបាលនៅក្នុងក្រុមប្រឹក្សាដឹកនាំបានរារាំងភាពចម្រុះ និងមានឥទ្ធិពលអវិជ្ជមានមកលើប្រតិបត្តិការរបស់មូលនិធិនេះ ដែលនេះជាកិច្ចការមួយដែលត្រូវបានដោះស្រាយនៅពេលក្រោយមក។ ការសន្និដ្ឋានបែបនេះមានភាពស្របគ្នាជាមួយទស្សនៈដទៃទៀតអំពីមូលនិធិអភិរក្សអន្តរជាតិ ដែលបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបញ្ចៀសវត្តមានច្រើនលើសលប់របស់តំណាងពីរដ្ឋាភិបាលនៅក្នុងអង្គភាពដឹកនាំ ទន្ទឹមនឹងការរក្សាបានយ៉ាងហោចណាស់តំណាងជាន់ខ្ពស់មួយរូបពីរដ្ឋាភិបាល ដែលជាគន្លឹះសម្រាប់ជោគជ័យនៃមូលនិធិនានា។[2]

រចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចនិងអំណាចក្នុងការបោះឆ្នោតរបស់អង្គភាពខុសៗគ្នា នៅក្រុមប្រឹក្សាភិបាលទំនងជាមានភាពខុសគ្នាជាខ្លាំង។ មូលនិធិខ្លះប្រើប្រាស់ការសម្រេចដោយការឯកភាពមតិទាំងស្រុង ចំណែកមូលនិធិផ្សេងទៀតប្រកាន់យកការសម្រេចដោយសម្លេងឆ្នោតភាគច្រើន។ ដូចគ្នានេះដែរ មូលនិធិខ្លះ ផ្តល់ឲ្យសមាជិកម្នាក់ៗនៅក្នុងក្រុមប្រឹក្សាភិបាលមួយសម្លេង ចំណែកមូលនិធិអាម៉ាហ្សូន ផ្តល់ឲ្យក្រុមអ្នកពាក់ព័ន្ធនីមួយៗ (រដ្ឋាភិបាលថ្នាក់ជាតិ រដ្ឋាភិបាលថ្នាក់មូលដ្ឋាន អង្គការសង្គមស៊ីវិល) នូវសម្លេងឆ្នោតរួមគ្នាតែមួយ។ ជម្រើសនៃគោលការណ៍បោះឆ្នោត អាចមានឥទ្ធិពលជាសំខាន់មកលើតុល្យភាពអំណាចនៅក្នុងក្រុមប្រឹក្សាភិបាល និងគួរតែពិចារណាជាមួយគ្នា នឹងនិយមន័យអំពីសមាសភាពនៃក្រុមប្រឹក្សាភិបាលផងដែរ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល** តាមធម្មតា រួមបញ្ចូលកិច្ចការនានា ដូចជា ការអនុម័តគោលនយោបាយ និងយុទ្ធសាស្រ្តផ្តល់មូលនិធិ ការពិនិត្យតាមដាន និងការពិនិត្យគុណផលនៃមូលនិធិ ការគិតគូរអំពីគោលការណ៍

[2] Spergel, B. and Taïeb, P. Rapid Review of Conservation Trust Funds. Conservation Finance Alliance Working Group on Environmental Funds (p. 27-29). 2008. មាននៅក្នុង: http://www.conservation.org/global/gcf/Documents/rapid_review.pdf.

ណែនាំសម្រាប់ការវិនិយោគ និងការបង្កើតបទបញ្ញា និងលក្ខខណ្ឌសម្រាប់កម្ចី/ជំនួយឥតសំណងផងដែរ។ នៅក្នុងករណីខ្លះ ក្រុមប្រឹក្សាភិបាលក៏មានការទទួលខុសត្រូវលើការអនុម័តថវិកា ឬសំណើសុំមូលនិធិផងដែរ ជាពិសេស សម្រាប់គម្រោងខ្នាតធំ។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍ពីCBFF បង្ហាញអំពីចំនួនយ៉ាងច្រើននៃសំណើសុំមូលនិធិដែលពាក់ព័ន្ធ ដូច្នេះការកំហិតលើការពាក់ព័ន្ធនៃក្រុមប្រឹក្សាភិបាលនៅក្នុងការសម្រេចនានាលើសំណើដែលមានទឹកប្រាក់ច្រើនជាងកម្រិតណាមួយនោះ អាចជួយបង្កើនប្រសិទ្ធិភាពការងារយ៉ាងច្រើនផងដែរ។

**អង្គភាពគ្រប់គ្រង** តាមធម្មតារួមមាន ក្រុមបុគ្គលិកជំនាញឯកទេសដែលធ្វើការពេញម៉ោង ដែលក្នុងករណីជាច្រើន ដឹកនាំដោយនាយកប្រតិបត្តិមួយរូប។ ជាញឹកញាប់ មុខងាររបស់អ្នកទាំងនេះរួមបញ្ចូល ការគ្រប់គ្រងលើប្រតិបត្តិការ និងហិរញ្ញវត្ថុនៃមូលនិធិ ការគិតគូរអំពីយុទ្ធសាស្ត្រនានា និងផែនការសម្រាប់បង្ហាញជូនទៅក្រុមប្រឹក្សាភិបាល ការអនុម័ត ឬលើកសំណើមូលនិធិជាមុន ដូចក្នុងករណី EPF នៃប្រទេសឡាវ ការផ្តល់ជំនួយដល់អ្នកទទួលមូលនិធិនៅក្នុងការរៀបចំសំណើសុំមូលនិធិ។

ជាញឹកញាប់ អង្គភាពគ្រប់គ្រងទទួលការគាំទ្រពី**ទីភ្នាក់ងារនានានៃរដ្ឋាភិបាលឬអង្គការអន្តរជាតិ**។ ឧទា. PROFONANPE បានទទួលការគាំទ្រក្នុងការពិនិត្យតាមដានខាងបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់កម្មវិធី និងគម្រោងខុសៗគ្នារបស់ខ្លួន ពីសំណាក់ស្ថាប័នពាក់ព័ន្ធចំនួនពីរពោលគឺ នាយកដ្ឋានហិរញ្ញវត្ថុនិងរដ្ឋបាល និងនាយកដ្ឋានអភិវឌ្ឍន៍ និងចាត់ចែងត្រួតពិនិត្យ។ នៅក្នុងពេលបច្ចុប្បន្ននេះ នៅក្រោម GRIF អង្គភាពជាដៃគូដូចជា ធនាគារពិភពលោក និង UNDP ជួយអង្គភាពអនុវត្តគម្រោង ក្នុងការបង្កើតឯកសារគោលគំនិតគម្រោង និងសំណើគម្រោង និងមានភារៈទទួលខុសត្រូវលើការណែនាំ និងការត្រួតពិនិត្យលើឯកសារនិងសំណើគម្រោងទាំងនោះ។

បន្ថែមលើអង្គភាពនានាដែលបានបង្ហាញខាងលើ មូលនិធិជាច្រើនក៏ប្រើប្រាស់**រចនាសម្ព័ន្ធត្រាស់**(គ្រប់គ្រងជំនួស)ដើម្បីចាត់ចែងមូលនិធិទាំងនេះផងដែរ។ នៅក្នុងករណីរ៉េដបូក និងមូលនិធិអាកាសធាតុជាតិ ជាញឹកញាប់ រចនាសម្ព័ន្ធនេះក៏បានផ្តល់ដោយអង្គការអន្តរជាតិផងដែរ ដូចជាធនាគារអភិវឌ្ឍន៍អាហ្វ្រិក (ដូចនៅក្នុងករណី CBFF) ឬ UNDP (ដូចនៅក្នុងករណី ICCTF)។ នៅក្រោមមូលនិធិព្រៃឈើជាតិភាគច្រើន ក៏ដូចជា មូលនិធិអាម៉ាហ្សូនផងដែរ ធនាគារជាតិមួយ បានដើរតួជាអ្នកគ្រប់គ្រងជំនួស។

តាមធម្មតា អ្នកគ្រប់គ្រងជំនួសមានភារៈទទួលខុសត្រូវជានាលើការគ្រប់គ្រង និងការវិនិយោគមូលនិធិនានាអនុលោមតាមគោលនយោបាយ និងសេចក្តីណែនាំរបស់ក្រុមប្រឹក្សាភិបាល។ អ្នកគ្រប់គ្រងជំនួសស្ថិតក្នុង**ការទទួលខុសត្រូវលើការជានា**ក្នុងកម្រិតខុសៗគ្នា។ នៅក្នុងករណីជាច្រើន ទិដ្ឋភាពខ្លះៗនៃការទទួលខុសត្រូវលើការជានា ក៏មានអនុវត្តចំពោះអង្គភាពដទៃទៀតផងដែរ ដូចជា តាមធម្មតា ត្រូវពិនិត្យមើលទំនាស់ផលប្រយោជន៍ ដូចជាក្នុងករណីនាយកប្រតិបត្តិ ចំណែកបុគ្គលិក ត្រូវគោរពតាមក្រមសីលធម៌មួយចំនួន។ នៅក្នុងករណី ICCRF ទីភ្នាក់ងារប្រតិបត្តិ ក៏ត្រូវមានភារៈទទួលខុសត្រូវលើការជានាផងដែរ។

មានករណីមួយចំនួន ដែល**អង្គភាពក្នុងវិស័យឯកជន** ក៏ត្រូវបានរួមបញ្ចូលទៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចផងដែរ។ នៅក្នុងករណី CBFF ភ្នាក់ងារគ្រប់គ្រងមូលនិធិមួយមកពីវិស័យឯកជន (សមាហាគម SNV និងប្រាយវ៉តធ័រហោសគូព័រ) បានចូលរួមក្នុងការត្រួតពិនិត្យគម្រោងតូចៗ ចំណែកនៅក្រោម FONAFIFO អង្គភាពក្នុងវិស័យឯកជន ដែលត្រូវគេស្គាល់ថាជា*អ្នកទទួលសិទ្ធិ* ត្រូវបានប្រើប្រាស់ ដើម្បីពិនិត្យតាមដានគុណផលនៃការផ្តល់មូលនិធិដល់អ្នកទទួលជាច្រើន។ នៅក្នុងករណីនីមួយៗ ការប្រើប្រាស់អង្គភាពបែបនេះ ត្រូវបានរាយការណ៍ថាបានជួយសម្រួលឲ្យមានការបង្កើនប្រសិទ្ធ

ភាពយ៉ាងច្រើន ទោះបីបទពិសោធន៍នៅក្រោម FONAFIFO គូសបញ្ជាក់ផងដែរអំពីតម្រូវការឲ្យមានការធ្វើសវនកម្មជាទៀងទាត់ និងពិស្តារលើអង្គភាពទាំងនោះ ដើម្បីការពារទល់នឹងទំនាស់ផលប្រយោជន៍ក៏ដោយ។

ភស្តុតាងពីមូលនិធិរ៉េដបូក និងមូលនិធិអាកាសធាតុជាតិ បង្ហាញថា គ្រឹះស្ថានឯកជន ឬ ធនាគារជាតិ អាចចាត់ចែងរដ្ឋបាលលើមូលនិធិនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងគ្រឹះស្ថានអន្តរជាតិធំៗ ដូចជា UNDP ឬធនាគារពិភពលោកទៅទៀត។ នៅក្នុងករណី ICTFF ថ្លៃចំណាយលើការចាត់ចែងរដ្ឋបាលរបស់ UNDP មានប្រមាណ ១២% ចំណែកធនាគារពិភពលោក តាមធម្មតា យកកម្រៃរវាង ១០-១៥% សម្រាប់គ្រប់គ្រងមូលនិធិ។[3] សម្បទាត្រាស់នៃមូលនិធិអាម៉ាហ្សូន យកកម្រៃត្រឹមតែ ៣% ប៉ុណ្ណោះសម្រាប់កម្រៃរដ្ឋបាល។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពអនុវត្តនៃមូលនិធិ ពោលគឺធនាគារអភិវឌ្ឍន៍ជាតិ BNDES ជាអ្នកស្រូបយកថ្លៃចំណាយរដ្ឋបាលយ៉ាងច្រើន។

បទពិសោធន៍ជាមួយ CBFF បង្ហាញថា ការប្រើប្រាស់ភ្នាក់ងារគ្រប់គ្រងមូលនិធិ បានបង្កើនប្រសិទ្ធភាពនៃសំណើគម្រោង ដោយមានការចំណាយទាបជាខ្លាំងធៀបនឹងលេខាធិការដ្ឋានដែលដឹកនាំដោយធនាគារអភិវឌ្ឍន៍អាហ្វ្រិក (AfDB)។ FMA ត្រូវបានតែងតាំងនៅក្នុងឆ្នាំ២០១១ ជាភ្នាក់ងារគ្រប់គ្រងមូលនិធិ សម្រាប់រយៈពេលមួយឆ្នាំ ដែលបានឃើញតួលេខនៃការអនុម័តគម្រោងកើនឡើងដល់ ៩២៣%។ សព្វថ្ងៃនេះ FMA ចាត់ចែងគ្រប់គ្រងជិត ៨០% នៃគម្រោងដែលបានអនុម័ត ទន្ទឹមនឹងប្រតិបត្តិការក្នុងកម្រិតចំណាយសម្រាប់ឆ្នាំ២០១១-២០១៤ ដែលមានប្រមាណ ៣៥% ទាបជាងការចំណាយរដ្ឋបាលរបស់ AfDB សម្រាប់តែក្នុងឆ្នាំ ២០១០ ប៉ុណ្ណោះ។

មូលនិធិអាម៉ាហ្សូន និង ICCTF ក៏បានរួមបញ្ចូល**គណៈកម្មាធិការបច្ចេកទេស** ទៅក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល នៃមូលនិធិរបស់ពួកគេផងដែរ បើទោះជាពួកគេមានមុខងារខុសគ្នាដោយឡែកនៅក្នុងមូលនិធិនីមួយៗក៏ដោយ។ សម្រាប់មូលនិធិអាម៉ាហ្សូន គណៈកម្មាធិការបច្ចេកទេសទទួលខុសត្រូវទាំងស្រុងលើការបង្កើតវិធីសាស្ត្រ ដើម្បីពិនិត្យមើលការប្រែប្រួលស្តុកកាបូនព្រៃឈើនិងប៉ាន់ស្មានអំពីការកាត់បន្ថយនូវការបំភាយសម្រាប់ការបង់ថ្លៃទៅតាមគុណផល។ ក្នុងការប្រៀបធៀប គណៈកម្មាធិការបច្ចេកទេសនៃICCTF ត្រូវបានបង្កើតឡើងដើម្បីពិនិត្យផ្នែកបច្ចេកទេសនៃសំណើគម្រោង និងលើកអនុសាសន៍ដល់ពួកគេសម្រាប់ការអនុម័ត ដោយផ្អែកលើគុណសម្បត្តិខាងបច្ចេកទេសរបស់ពួកគេ។

## ២.៣ ការវិនិយោគធនធានពីមូលនិធិ

**ចំណុចគន្លឹះ:**

- ការវិនិយោគលើទ្រព្យសកម្មសម្រាប់ការអភិរក្ស ដែលផ្តល់លទ្ធភាពក្នុងការប្រើប្រាស់មូលធនងាយបម្លែង ដើម្បីលៃទុកមូលនិធិឲ្យមានជានិច្ចសម្រាប់ការផ្ទេរ គឺជាជម្រើសដែលមូលនិធិជាច្រើនប្រកាន់យក
- មូលនិធិដែលមានដើមទុនគ្រប់គ្រាន់ អាចធានានិរន្តរភាពរយៈពេលវែង តាមរយៈការបង្កើតមូលនិធិទាយជ្ជទាន ដែលផ្តល់ការប្រាក់ប្រចាំឆ្នាំគ្រប់គ្រាន់សម្រាប់មូលនិធិ ដល់ផ្នែកណាមួយនៃប្រតិបត្តិការ
- បទពិសោធន៍ជាមួយមូលនិធិអាម៉ាហ្សូន បង្ហាញថា គេអាចទទួលបានផលចំណូលជាច្រើនពីការវិនិយោគ ដោយធ្វើឲ្យអ្នកគ្រប់គ្រងមូលនិធិដែលមានជំនាញវិជ្ជាជីវៈខាងផ្នែកនេះបានចូលរួម
- ការអនុម័តគោលការណ៍ណែនាំសម្រាប់ការវិនិយោគដែលរួមបញ្ចូលប្រព័ន្ធសុវត្ថិភាព សម្រាប់ការពារការវិនិយោគនៅក្នុងបរិយាកាសនៃការអនុវត្តដែលបង្កគ្រោះថ្នាក់ចំពោះបរិស្ថាន គឺជាស្តង់ដារនៃការអនុវត្ត។

http://www.odi.org.uk/sites/odi.org.uk/files/odi-assets/publications-opinion-files/8340.pdf.

គ្រប់មូលនិធិដែលបានសិក្សា លើកលែងតែ ICCTF បានប្រឹងប្រែងវិនិយោគយ៉ាងហោចណាស់ មូលនិធិរបស់ខ្លួនខ្លះៗតាមវិធីណាមួយ។ នៅក្នុងករណីភាគច្រើន ការទទួលខុសត្រូវលើការវិនិយោគធនធានពីមូលនិធិ ធ្វើឡើងដោយអ្នកគ្រប់គ្រងជំនួស ស្របតាម**គោលនយោបាយ និងគោលការណ៍ណែនាំ** ដែលចែងដោយក្រុមប្រឹក្សាភិបាលនៃមូលនិធិ ទោះបីអ្នកផ្តល់យោបល់ខាងការវិនិយោគក៏អាចចូលរួមក្នុងការផ្តល់យោបល់ណែនាំជាយុទ្ធសាស្ត្រក៏ដោយ។ គោលនយោបាយបែបនេះ តាមធម្មតា មានគោលដៅឆ្ពោះទៅរក ***យុទ្ធសាស្ត្រវិនិយោគលើការអភិរក្ស*** ដែលពាក់ព័ន្ធជាមួយអចលនទ្រព្យដែលជាប្រភពចំណូល ដើម្បីធានាឲ្យមានភាពអាចព្យាករណ៍បាន និងសន្តិសុខ ទន្ទឹមនឹងផ្តល់ភាពចាំបាច់សម្រាប់លទ្ធភាពដោះដូរ ដើម្បីផ្តល់មូលនិធិដល់គម្រោងនានានៅក្រោយមានការអនុម័ត។ ទោះបីមានលក្ខណៈអភិរក្សបែបនេះក៏ដោយ មូលនិធិខ្លះបានទទួលជោគជ័យក្នុងការទទួលផលចំណូលមកវិញយ៉ាងច្រើន៖ មូលនិធិអាម៉ាហ្សូនបានទទួលផលចំណូល ៥-២០% នៅក្នុងរយៈពេលត្រឹមប៉ុន្មានឆ្នាំ ដោយបង្កើតជាមូលនិធិដាច់ដោយឡែក ដែលគ្រប់គ្រងដោយក្រុមហ៊ុនវិនិយោគឯកជនមួយ។

គោលនយោបាយ និងគោលការណ៍ណែនាំអាចបែងចែកខុសគ្នារវាងមូលនិធិក្នុងជំពូកមួយចំនួន ឬរវាងមូលនិធិវេង ឬគណនីខុសៗគ្នា ដែលជាញឹកញាប់ មានគោលដៅធានាឲ្យមានការវិនិយោគសម្រាប់រយៈពេលសមស្រប។ ឧទា. មូលនិធិទាយជ្ជទាន ភាគច្រើនត្រូវបានដាក់នៅក្នុងការវិនិយោគសម្រាប់រយៈពេលវែង ដែលតាមធម្មតានាំមកនូវផលចំណូលកម្រិតខ្ពស់ ដែលអាចផ្តល់ទាំងស្ថិរភាពនិងជាប្រភពប្រាក់ចំណូលដើម្បីផ្តល់មូលនិធិសម្រាប់ប្រតិបត្តិការផងដែរ។ ផ្ទុយទៅវិញមូលនិធិសម្រាប់វិនិយោគទៅអនាគត ជួនកាលត្រូវបានដាក់ទៅក្នុងការវិនិយោគរយៈពេលខ្លីដោយមានលទ្ធភាពដោះដូរកម្រិតខ្ពស់។ សារៈសំខាន់នៃបញ្ហានេះត្រូវបានគូសបញ្ជាក់នៅក្នុងសវនកម្មនៃ FFM ដែលបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការវាយតម្លៃដោយប្រុងប្រយ័ត្នអំពីបរិមាណមូលធនដែលអាចងាយដោះដូរ ដែលមូលនិធិនេះត្រូវរក្សាឲ្យមានជាប្រចាំ ដើម្បីធានាថា សាច់ប្រាក់ដែលមិនត្រូវការនៅក្នុងអំឡុងពេលណាមួយ ត្រូវបានវិនិយោគហួសអំឡុងពេលនោះ ក្នុងគោលដៅផ្តល់ផលចំណូលកម្រិតខ្ពស់។

ទោះបីការពិនិត្យនេះមិនបានវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យសង្គម និងបរិស្ថានដែលត្រូវប្រើប្រាស់នៅក្នុងការវិនិយោគក៏ដោយ ការពិនិត្យដាច់ដោយឡែកមួយលើមូលនិធិអភិរក្សបានរកឃើញថា ភាគច្រើននៃមូលនិធិអភិរក្ស ឥឡូវនេះ ប្រើប្រាស់នីតិវិធីដែលមានកត្តាបរិស្ថានជាលក្ខណៈវិនិច្ឆ័យ សម្រាប់ការវិនិយោគនានារបស់ខ្លួន ដែលរួមទាំង តាមរយៈធ្វើការជាមួយក្រុមហ៊ុននានា ដើម្បីលើកកំពស់ទម្លាប់ដែលមានមេត្រីភាពជាមួយបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ ការពិនិត្យសំណើគម្រោងវិនិយោគដែលផ្អែកលើលក្ខណៈវិនិច្ឆ័យនៃភាពទទួលខុសត្រូវខាងសង្គម មិនសូវមានជាទូទៅឡើយ ដោយសារ វាត្រូវការពេលច្រើន និងត្រូវចំណាយច្រើន។[4]

## ២.៤ ភាពសមស្រប និងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស

[4] Spergel, B. and Taïeb, P. Rapid Review of Conservation Trust Funds, Conservation Finance Alliance Working Group on Environmental Funds (p. 58-59). 2008. មាននៅក្នុង http://www.conservation.org/global/gcf/Documents/rapid_review.pdf.

**ចំណុចគន្លឹះ:**

- អនុញ្ញាតឲ្យអង្គភាពខុសៗគ្នាជាច្រើនទទួលមូលនិធិ ដែលរួមទាំង អង្គភាពក្នុងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នមិនមែនរដ្ឋាភិបាលនិងគ្រឹះស្ថានអប់រំ អាចពង្រីកលទ្ធភាពទទួលបានមូលនិធិនិងកែលម្អគុណផល និងលក្ខណៈឌីណាមិកនៃមូលនិធិផងដែរ
- នៅក្នុងការកំណត់ដំណើរការនៃការដាក់ពាក្យសុំមកមូលនិធិនេះ ប្រការសំខាន់ត្រូវធ្វើឲ្យមានតុល្យភាពគ្នារវាងការធានាឲ្យមានការពិនិត្យបានម៉ត់ចត់លើពាក្យសុំ ដោយពិចារណាផងដែរអំពីសមត្ថភាពក្នុងកម្រិតកំណត់របស់អ្នកដាក់ពាក្យសុំ ដូចជា តាមរយៈការប្រើប្រាស់ដំណើរការខុសៗគ្នា ចំពោះបរិមាណមូលនិធិខុសគ្នា និងការគាំទ្រដល់ពាក្យសុំ ដែលកំពុងស្ថិតក្នុងដំណើរការនេះ
- អាចអនុញ្ញាឲ្យមានការប្រើប្រាស់អង្គការអន្តរជាតិជាអង្គភាពដៃគូ ដើម្បីជួយក្នុងការអនុវត្តគម្រោង។

លក្ខណៈសមស្របនិងលក្ខណៈវិនិច្ឆ័យជ្រើសរើស ជាទូទៅត្រូវបានក្រុមប្រឹក្សាភិបាលជាអ្នកកំណត់ ដើម្បីជ្រើសរើស និងបំពេញគោលដៅជាយុទ្ធសាស្ត្រ និងអាណត្តិនៃមូលនិធិ។ មូលនិធិរេដបូក ដែលបានសិក្សាទាំងនេះ បានបង្ហាញអំពីវិធានខុសៗគ្នា ក្នុងការកំណត់**សកម្មភាពដែលសមស្រប**។ ឧទា. GRIF សព្វថ្ងៃនេះ ផ្តោតលើការកសាងសមត្ថភាព និងការអភិវឌ្ឍសេដ្ឋកិច្ចកាបូនទាប ជាងគម្រោងកាត់បន្ថយការបំភាយ ដោយសារតែព្រៃឈើនៃប្រទេសហ្គុយយ៉ាណាមិនមែនជាប្រភពចំបងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់។ ម៉្យាងវិញទៀត មូលនិធិ CBFF ទំនងជាផ្តល់មូលនិធិសម្រាប់តែគម្រោងណាដែលកាត់បន្ថយការបំភាយដោយផ្ទាល់តែប៉ុណ្ណោះ ចំណែកមូលនិធិអាម៉ាហ្សូន ផ្តល់សាច់ប្រាក់ដល់ទាំងគម្រោងដែលកាត់បន្ថយការបាត់បង់ព្រៃឈើដោយផ្ទាល់ និងដល់កិច្ចប្រឹងប្រែងកសាងសមត្ថភាពផងដែរ។ មូលនិធិមួយចំនួនប្រើប្រាស់យន្តការដាច់គ្នា ពោលគឺ មូលនិធិរង ឬ ចរន្តនៃការផ្តល់មូលនិធិសម្រាប់សកម្មភាពក្នុងជំពូកខុសៗគ្នា។

**អង្គភាពដែលមានលក្ខណៈសមស្របក្នុងការទទួលមូលនិធិ** មានការទាក់ទងជិតស្និទ្ធជាមួយគោលបំណងរួម និងទំហំនៃមូលនិធិ។ ចំពោះមូលនិធិដែលមានគោលដៅអភិរក្សតំបន់គ្រប់គ្រងដោយរដ្ឋាភិបាល ដូចជាPROFONANPE ការផ្តល់មូលនិធិនឹងផ្តោតជាបឋមចំពោះអង្គភាពរដ្ឋាភិបាល ដូចជា អាជ្ញាធរតំបន់ការពារធម្មជាតិ។ ម៉្យាងវិញទៀត មូលនិធិដែលមានគោលដៅអភិរក្សតំបន់ដែលគ្រប់គ្រងដោយឯកជន ដូចជា FONAFIFO, FFM ឬ EPF នៃប្រទេសឡាវ នឹងផ្តោតការផ្តល់មូលនិធិដល់ម្ចាស់ព្រៃឈើឯកជន ឬ សហគមន៍។ មូលនិធិរេដបូកមួយចំនួន មានគោលដៅផ្តល់ទៅឲ្យព្រៃឈើដែលគ្រប់គ្រងដោយឯកជន សហគមន៍និងរដ្ឋាភិបាល តាមរយៈយន្តការមួយចំនួនរួមបញ្ចូលគ្នា។ ឧទា. នៅក្រោមមូលនិធិអាម៉ាហ្សូន ៤៨% នៃការផ្តល់មូលនិធិដែលបានផ្ទេរទៅឲ្យគម្រោង ត្រូវបានវិភាជន៍ដល់អ្នកទទួលក្នុងវិស័យឯកជន ឬ អង្គការមិនមែនរដ្ឋាភិបាល ចំណែក ៤៥% នៃមូលនិធិត្រូវបានវិភាជន៍សម្រាប់គម្រោងដែលនាំមុខដោយរដ្ឋាភិបាល និងផ្នែកដែលនៅសល់គឺសម្រាប់សកលវិទ្យាល័យ។ GRIF អនុញ្ញាតឲ្យអង្គភាពក្នុងវិស័យឯកជនចូលរួម ប៉ុន្តែតម្រូវឲ្យមានការអនុម័តឯកភាពជាមុនពីអង្គភាពជាដៃគូ (ធនាគារពិភពលោក IDB ឬ UNDP) ដើម្បីរួមបញ្ចូល សម្រាប់ត្រួតពិនិត្យមើលការបង្កើត និងអនុវត្តគម្រោង។ ផ្ទុយទៅវិញ មូលនិធិ ICCTF តម្រូវឲ្យគម្រោងទាំងអស់ ស្ថិតក្រោមការដឹកនាំនៃក្រសួងពាក់ព័ន្ធ ឬ ទីភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់ជាតិ ឬ ថ្នាក់មូលដ្ឋាន ដែលជាកត្តាមួយត្រូវបានគេអះអាងថា បានរួមចំណែកដល់គម្រោងតែបីគត់ ដែលបានអនុម័តរួចមកទល់ពេលនេះ។

**លក្ខខណ្ឌឲ្យមាននីតិវិធី** ជាញឹកញាប់មានភាពខុសគ្នា អាស្រ័យលើប្រភេទ និងទំហំគម្រោង។ នៅក្នុងមូលនិធិ EDF នៃប្រទេសឡាវ គំរូដាក់ពាក្យសុំចំនួន ៥-៦ទំព័រ ដែលដាក់ជូនមកប្រទេសឡាវ គឺជាលក្ខខណ្ឌសម្រាប់គម្រោងខ្នាតតូច (រហូតដល់ ៦០.០០០ដុល្លាអាមេរិក) ចំណែកគម្រោងខ្នាតធំ ត្រូវមានការដាក់ជូនសំណើគម្រោងពិស្តារជាភាសាអង់គ្លេស។ ការគាំទ្រដល់ការរៀបចំសេចក្តីព្រាងសំណើ ត្រូវបានផ្តល់ទាំងសម្រាប់អ្នកដាក់ពាក្យសុំគម្រោងខ្នាតតូច និងខ្នាតធំ។ នៅក្នុងករណីប្រព័ន្ធ PES ក៏មានលក្ខខណ្ឌតម្រូវឲ្យមានកម្មសិទ្ធិដីផងដែរ ទោះបីលក្ខខណ្ឌនេះត្រូវបានទិទៀនថា មានភាពលំអៀងខ្លាំងពេក ហើយនៅក្នុងករណីខ្លះមិនបានផ្តល់ភាពទាក់ទាញឡើយសម្រាប់អ្នកចូលរួមក្នុងជំពូកខ្លះ (ដូចជា សហគមន៍ជនជាតិដើមនៅក្រោម FONAFIFO)។ សម្រាប់ប្រព័ន្ធប្រាក់កម្ចី ការតម្រូវឲ្យមានភស្តុតាងនៃឥណទានដែលប្រើការបាន និងការផ្តល់វត្ថុបញ្ចាំ គឺជាលក្ខខណ្ឌដែលត្រូវបានដាក់ឲ្យអនុវត្តជាទូទៅ។ មូលនិធិរ៉េដបូក និងមូលនិធិជាតិប្រែប្រួលអាកាសធាតុខ្លះ ដូចជា CBFF មូលនិធិអាម៉ាហ្សូន និង ICCTF ប្រើប្រាស់គំរូស្តង់ដារនៃពាក្យសុំ ចំណែកមូលនិធិខ្លះទៀតបានស្នើឲ្យអ្នកដាក់ពាក្យសុំដែលមានភ្ជាប់ឯកសារគោលគំនិតសម្រាប់គម្រោង ដោយមិនសូវមានភាពតឹងតែងលើទម្រង់ដែលត្រូវរៀបចំសម្រាប់សុំមូលនិធិនោះឡើយ។

ទាក់ទងនឹង**រយៈពេលគម្រោង** មូលនិធិរ៉េដបូក ច្រើនតែផ្តោតលើរយៈពេលខ្លី ទៅមធ្យម។ ឧទា. CBFF ផ្តល់មូលនិធិដល់គម្រោងនានានៅក្នុងរយៈពេលបីឆ្នាំ ចំណែកមូលនិធិអាម៉ាហ្សូន ផ្តល់មូលនិធិដល់គម្រោងដែលមានរយៈពេល ២-៤ឆ្នាំ។ មូលនិធិ PROFONANPE ដែលផ្តោតលើការអភិរក្សតំបន់ការពារធម្មជាតិរបស់ជាតិ ច្រើនតែផ្តល់មូលនិធិដល់គម្រោងដែលមានរយៈពេលវែង ទោះបីប្រើប្រាស់អំឡុងពេលនៃការពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីធានាឲ្យមានការកែប្រែគោលដៅតាមការចាំបាច់ក៏ដោយ។

## ២.៥ ការវាយតម្លៃ និង MRV

### ២.៥.១ ការវាយតម្លៃលើគុណផលជារួមនៃមូលនិធិ

**ចំណុចគន្លឹះ:**

- តាមធម្មតា ក្រុមប្រឹក្សាភិបាលធ្វើការពិនិត្យមើលប្រចាំឆ្នាំ ឬ ប្រចាំឆមាស លើគុណផលជារួមនៃមូលនិធិ និងកែសម្រួលគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនឲ្យបានសមស្រប
- ការធ្វើឲ្យមានភាគីទីបីចូលរួមគឺជាស្តង់ដារនៃការអនុវត្ត ដើម្បីធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ អនុលោមតាមស្តង់ដារអន្តរជាតិ ចំណែកមូលនិធិខ្លះក៏ចែងអំពីការតម្រូវឲ្យធ្វើសវនកម្មការកាត់បន្ថយការបំភាយ ឬកត្តាដទៃទៀតផងដែរ
- ការពិនិត្យមើលឯកសារនានាដែលមានជាសាធារណៈ ក៏ត្រូវបានចាត់ទុកជាទម្លាប់ល្អផងដែរ
- ម្ចាស់ជំនួយខ្លះ អាចស្នើសុំឲ្យមានការពិនិត្យជាពិសេសលើមូលនិធិនេះ ដែលតាមធម្មតា ម្ចាស់ជំនួយជាអ្នកចេញថ្លៃចំណាយ។

នៅក្នុងករណីភាគច្រើន **ការពិនិត្យជារួមលើគុណផលនៃមូលនិធិ** ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល តាមរយៈការពិនិត្យប្រចាំឆ្នាំ ឬប្រចាំឆមាស។ ជាទូទៅ របាយការណ៍ត្រូវបានអង្គភាពប្រតិបត្តិជាអ្នករៀបចំ និងរួមបញ្ចូលចំណុចពិស្តារអំពីទាំងគុណផលខាងហិរញ្ញវត្ថុ និងផ្នែកសំខាន់ៗដទៃទៀតផងដែរ ដែលរួមទាំង ការពិនិត្យដោយក្រុម

ប្រឹក្សាភិបាល លើគម្រោង និងគុណផលនៃគម្រោងទាំងនោះ។ របាយការណ៍ដែលតាមធម្មតាក្រុមប្រឹក្សាភិបាលគឺជាអ្នកអនុម័តឯកភាព នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ឬដូចករណីក្នុងក្របខ័ណ្ឌ EPF នៃប្រទេសឡាវ ត្រូវបានដាក់ជូនទៅរដ្ឋាភិបាល ដែលត្រូវម្ចាស់ជំនួយចាត់ទុកថាជាទិដ្ឋភាពមួយនៃទម្លាប់ល្អ។

### ២.៥.២ MRV នៃសកម្មភាពនីមួយៗដែលបានទទួលមូលនិធិ

**ចំណុចគន្លឹះ:**

- លក្ខខណ្ឌ MRV តាមធម្មតាមានការផ្សារភ្ជាប់ទៅនឹងប្រភេទនិងទំហំគម្រោង និងអ្នកទទួលមូលនិធិពីគម្រោង
- នៅក្នុងមូលនិធិរ៉េដបូកភាគច្រើន ការចាត់ចែង MRV តាមធម្មតាត្រូវតែមានការឯកភាពគ្នាលើមូលដ្ឋានជាក់លាក់នៃគម្រោង
- ការប្រើប្រាស់អង្គភាពក្នុងវិស័យឯកជនអាចកាត់បន្ថយថ្លៃចំណាយ ប៉ុន្តែបង្កើនហានិភ័យនៃទំនាស់ផលប្រយោជន៍។

គំរូ MRV ដែលបានដាក់ឲ្យប្រើប្រាស់នៅកម្រិតគម្រោង តាមធម្មតា អាស្រ័យលើ**ប្រភេទ និងទំហំនៃគម្រោង។** PROFONANPE ដែលពាក់ព័ន្ធជាមួយគម្រោងខ្នាតធំ តាមធម្មតាដឹកនាំដោយស្ថាប័នរដ្ឋ ត្រូវការឲ្យមានរបាយការណ៍ជាទៀងទាត់ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ (នៅកម្រិតពិស្តារខុសៗគ្នា) អំពីលទ្ធផលនៃគម្រោង បញ្ហា និងថវិកាដែលត្រូវបង្ហាញជូនទៅក្រុមប្រឹក្សាដឹកនាំ ទន្ទឹមនឹងការអនុម័តយល់ព្រមលើថវិកាប្រចាំឆ្នាំ ដែលធ្វើឡើងដែលភ្ជាប់ដោយលក្ខខណ្ឌដែលមានកំណត់ជាសូចនាករកាលពីឆ្នាំមុន។

សម្រាប់គម្រោងតូចជាងដែលអនុវត្តដោយវិស័យឯកជន ឬ អង្គការមិនមែនរដ្ឋាភិបាល តាមធម្មតាមានការពិនិត្យតាមដាន ដែលធ្វើឡើងតាមរយៈរបាយការណ៍ប្រចាំឆ្នាំទៅអង្គភាពប្រតិបត្តិ ឬ ដូចក្នុងករណី GRIF គឺរាយការណ៍ទៅអង្គភាពដៃគូ។ នៅក្នុងករណីមូលនិធិរ៉េដបូក ផែនការពិស្តារអំពី MRV ដែលរួមទាំង សូចនាករគុណផល និងកាលវិភាគសម្រាប់ការពិនិត្យតាមដាន តាមធម្មតាត្រូវបានបង្កើតឡើងទៅតាមគម្រោងនីមួយៗ ប៉ុន្តែគម្រោងស្ទើរតែទាំងអស់ត្រូវតែដាក់ឲ្យធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ។

នៅក្នុងករណីដែលមានស្ថាប័នច្រើនជាអ្នកទទួលមូលនិធិ ដូចជាក្នុងប្រព័ន្ធ PES **ការជួលស្ថាប័នពីក្រៅដើម្បីអនុវត្ត MRV** អាចកាត់បន្ថយថ្លៃចំណាយ។ នៅក្រោមមូលនិធិ FPNAFIFO ភ្នាក់ងារក្នុងវិស័យឯកជនធ្វើការពិនិត្យតាមដានលើអ្នកចូលរួមនៅក្នុង PES ដែលបន្ទាប់មកនឹងត្រូវទទួលថ្លៃសេវាសម្រាប់ការពិនិត្យតាមដានពីអ្នកចូលរួមទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រការនេះបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ ដែលត្រូវឲ្យមានការធ្វើសវនកម្មលើភ្នាក់ងារទាំងនេះជាទៀងទាត់។

នៅទីបំផុត ក្នុងករណីដែលអ្នកទទួលមូលនិធិមានសមត្ថភាពទាប **ការធ្វើរបាយការណ៍ងាយៗ**អាចកាត់បន្ថយបន្ទុកមកលើអ្នកចូលរួម។ ឧទា. នៅក្រោមមូលនិធិ EDE នៃប្រទេសឡាវ របាយការណ៍ពីអ្នកទទួលមូលនិធិក្នុងបរិមាណតិចតួចបានធ្វើឡើងផ្ទាល់មាត់ តាមរយៈការប្រជុំរួមគ្នាដោយសារអ្នកទទួលជាច្រើនមានសមត្ថភាពតិចតួចក្នុងការសរសេររបាយការណ៍ពិស្តារ។

### ២.៥.៣ MRV នៃប្រព័ន្ធបង់ថ្លៃតាមគុណផល

**ចំណុចគន្លឹះ:**

- មកទល់ពេលនេះ គេពុំតម្រូវឲ្យមូលនិធិរេដបូកអនុវត្ត RL និងMRV ពេញលេញនោះទេ មុននឹងអាចទទួលបានការបង់ថ្លៃទៅតាមគុណផល។ ទោះជាយ៉ាងណាក៏ដោយ សូចនាករអភិរក្សត្រូវបានយកមកអនុវត្តនៅក្នុងករណីអវត្តមានវិធានការខាងលើ
- នៅក្នុងមូលនិធិខ្លះ មានការតម្រូវឲ្យអនុវត្តទៅតាមសូចនាករអភិបាលកិច្ច ដែលរួមទាំង ការបង្កើតប្រព័ន្ធRLs និងMRV ឲ្យបានរឹងមាំ ដែលជាលក្ខខណ្ឌមួយនៃការទទួលបានការបង់ថ្លៃបន្ថែម។

ការបង់ថ្លៃទៅតាមគុណផល តាមធម្មតាបានធ្វើឡើងនៅថ្នាក់ជាតិ ដោយផ្អែកលើការកាត់បន្ថយការបំភាយ នៅក្រោមកម្រិតយោង(RL)ដែលបានឯកភាពគ្នា។ នៅកម្រិតមូលដ្ឋាន ក្នុងករណីជាច្រើន កម្រិតនៃការវាស់វែងនេះជួបការលំបាក ដូច្នេះមិនសូវមានការប្រើប្រាស់ជាទូទៅឡើយ។ មូលនិធិដែលបានទទួលការបង់ថ្លៃពីរេដបូកទៅតាមគុណផល (GRID និងមូលនិធិអាម៉ាហ្សូន) មិនមានការរាំងស្ទះដោយសារតែមិនបានដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ RLs ឬ ប្រព័ន្ធ MRV រឹងមាំ ដែលមិនទាន់បានបង្កើតនៅក្នុងប្រទេសនោះឡើយ ហើយជាជំនួសបានប្រើប្រាស់ **ការប៉ាន់ស្មានកម្រិតទាប និងតួលេខជំនួសអំពីការបាត់បង់ព្រៃឈើ** ជាវិធានបណ្តោះអាសន្ន។ ឧទា. មូលនិធិអាម៉ាហ្សូន ប្រើប្រាស់ការអភិរក្ស ជា មេគុណដែលមានតម្លៃស្មើ ១០០តោនសមមូលឧស្ម័នកាបូនិក/ហិកតា សម្រាប់ការប៉ាន់ស្មានអំពីការបំភាយកាបូនពីតំបន់ព្រៃឈើ និងប្រើប្រាស់តួលេខគោលជាប្រវត្តិសាស្ត្រដែលមិនអាចកែប្រែបាន ដោយផ្អែកលើការធ្វើម៉ូដែល។ នៅក្នុងករណីប្រទេសហ្គុយយ៉ាណា រដ្ឋាភិបាលបានឯកភាពឲ្យមាន **សូចនាករសមត្ថភាព**សម្រាប់ទទួលការបង់ថ្លៃជាបន្ថែម ដែលរួមមាន ការបង្កើតកម្រិតយោង និងប្រព័ន្ធ MRV ដែលនឹងត្រូវរាយការណ៍នៅក្នុង UNFCCC ជាបីលំដាប់។ ទន្ទឹមនឹងនេះ កម្រិតនៃការបង់ថ្លៃក្នុងមួយតោនសមមូលឧស្ម័នកាបូនិក ត្រូវបានកាត់បន្ថយ ប្រសិនបើអត្រានៃការបាត់បង់ព្រៃឈើឈានហួសកម្រិតអតិបរមាដែលបានឯកភាពគ្នាជាមុន។

## ២.៦ ប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថាន

**ចំណុចគន្លឹះ:**

- ប្រព័ន្ធសុវត្ថិភាពរឹងមាំ មានសារៈសំខាន់បំផុតសម្រាប់ការទាក់ទាញមូលនិធិពីម្ចាស់ជំនួយនៅក្នុងមូលនិធិរេដបូក
- ក្នុងករណីដែលទទួលមូលនិធិពីម្ចាស់ជំនួយខុសៗគ្នាជាច្រើន យ៉ាងហោចណាស់ប្រព័ន្ធសុវត្ថិភាពត្រូវតែតឹងរ៉ឹងដូចប្រព័ន្ធដែលម្ចាស់ជំនួយនីមួយៗបានកំណត់ ដើម្បីបញ្ចៀសការតម្រូវឲ្យអនុវត្តប្រព័ន្ធសុវត្ថិភាពណាមួយរបស់ម្ចាស់ជំនួយសម្រាប់ចរន្តនីមួយៗនៃការផ្តល់មូលនិធិ។

វត្តមានប្រព័ន្ធរឹងមាំ សម្រាប់ការអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និងបរិស្ថាន ត្រូវបានចាត់ទុកថា**មានសារៈសំខាន់ណាស់សម្រាប់ការទាក់ទាញមូលនិធិពីម្ចាស់ជំនួយនានា**នៅក្នុងមូលនិធិរេដបូក ទោះបីនៅក្នុងមូលនិធិជាតិព្រៃឈើនិងបរិស្ថាន ដែលមានក្នុងកម្រិតទាបជាងនេះក៏ដោយ។ ម្ចាស់ជំនួយសាធារណៈអន្តរជាតិធំៗភាគច្រើនបំផុត តម្រូវឲ្យមានការ

ប្រើប្រាស់ប្រព័ន្ធស្តង់ដារសុវត្ថិភាពនៅក្នុងគម្រោង ឬ កម្មវិធីនានា ដែលជាគោលដៅនៃការផ្តល់មូលនិធិរបស់ខ្លួន ឬផ្ទុយទៅវិញ តម្រូវឲ្យមានប្រព័ន្ធសុវត្ថិភាពដែលមានភាពរឹងរ៉ឹងដូចគ្នា ឬតឹងរ៉ឹងជាងទៅទៀត។

ក្នុងករណីដែលស្វែងរកមូលនិធិពី**ម្ចាស់ជំនួយច្រើនខុសៗគ្នា** (ដែលជាករណីភាគច្រើន) មានការដាក់ឲ្យប្រើប្រាស់យុទ្ធសាស្ត្រចំបងៗចំនួនពីរ ដើម្បីធានាថាបំពេញបានតាមលក្ខខណ្ឌនៃប្រព័ន្ធសុវត្ថិភាពរបស់ពួកគេ។ យុទ្ធសាស្ត្រទីមួយពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពរបស់ម្ចាស់ជំនួយទៅតាមគម្រោងនីមួយៗដាច់ដោយឡែកពីគ្នា។ ឧទា. FONAFIFO អនុវត្តវិធាននេះ ដែលម្ចាស់ជំនួយអន្តរជាតិផ្តល់ត្រឹមតែមួយចំណែកតូចនៃមូលនិធិ ហើយជំនួយនេះផ្តោតលើគម្រោងជាក់លាក់តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត មូលនិធិដែលប្រើប្រាស់ប្រាក់ពីម្ចាស់ជំនួយសម្រាប់ផ្តល់ជាធនធានដល់សកម្មភាពគម្រោងជាច្រើនបែបខុសៗគ្នា ឬ មានបំណងទទួលមូលនិធិចម្រុះពីម្ចាស់ជំនួយតាមរយៈគណនីរួមមួយ ជាទូទៅត្រូវអនុវត្តប្រព័ន្ធសុវត្ថិភាពតឹងរ៉ឹងជាងនេះ ដែលទំនងជាត្រូវបំពេញតាមលក្ខខណ្ឌរបស់ម្ចាស់ជំនួយភាគច្រើន។ PROFOFANPE (ដែលកាលពីដំបូងបានបង្កើតមូលនិធិចាប់ផ្តើមពី GEF) អនុវត្តប្រព័ន្ធសុវត្ថិភាពរបស់ធនាគារពិភពលោក ចំណែកមូលនិធិអាម៉ាហ្សូន ប្រើប្រាស់ទាំងស្តង់ដារ SES របស់រេដបូក និងគោលនយោបាយ BNDES ដែលរួមបញ្ចូលលក្ខណៈវិនិច្ឆ័យអំពីការឯកភាពជាមុនដោយគ្មានការបង្ខំ (FPIC)។ ជាការប្រៀបធៀប EPF នៃប្រទេសឡាវបានបង្កើតក្របខ័ណ្ឌសុវត្ថិភាពបរិស្ថាន និងសង្គម (ESSF)របស់ខ្លួនផ្ទាល់ ដែលស្របជាមួយប្រព័ន្ធសុវត្ថិភាពរបស់ធនាគារពិភពលោក។

បន្ថែមលើលក្ខខណ្ឌខាងលើ មូលនិធិមួយចំនួន ដែលគ្រប់គ្រងនៅក្រោមការចាត់ចែងជំនួសពីអង្គការអន្តរជាតិនានា មានការតម្រូវឲ្យប្រើប្រាស់គោលនយោបាយសុវត្ថិភាពរបស់អង្គការទាំងនោះ។ ឧទា. នេះជាករណីសម្រាប់ CBFF ដែលប្រើប្រាស់គោលនយោបាយសុវត្ថិភាពរបស់ AfDB និងICCTF ដែលប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពរបស់UNDP។

## ២.៧ លក្ខខណ្ឌជាក់លាក់របស់ម្ចាស់ជំនួយ

**ចំណុចគន្លឹះ:**

- លក្ខខណ្ឌរបស់ម្ចាស់ជំនួយច្រើនតែឆ្លុះបញ្ចាំងអំពីអភិបាលកិច្ច និងកាលៈទេសៈដទៃទៀតនៃប្រទេសម្ចាស់ផ្ទះ ក៏ដូចជា គោលដៅជាយុទ្ធសាស្ត្រ និងផលប្រយោជន៍ជាតិរបស់ម្ចាស់ជំនួយផងដែរ
- តាមធម្មតា មូលនិធិនានាគ្រប់គ្រងលក្ខខណ្ឌរបស់ម្ចាស់ជំនួយ ដោយអនុវត្តលក្ខខណ្ឌទាំងនោះទៅតាមករណីនៃគម្រោងខុសៗគ្នា ឬ ប្រកាន់យកគោលការណ៍ និងនីតិវិធីម៉ឺងម៉ាត់សម្រាប់គ្រប់ទិដ្ឋភាពនៃអភិបាលកិច្ចមូលនិធិ ដែលទំនងជាបំពេញទៅតាមលក្ខខណ្ឌរបស់ម្ចាស់ជំនួយ។

ម្ចាស់ជំនួយដែលពិចារណាអំពីការរួមវិភាគទានទៅក្នុងមូលនិធិណាមួយ នឹងត្រូវពិនិត្យមើលអំពីប្រការដែលថាវិភាគទានរបស់ពួកគេនឹងត្រូវគ្រប់គ្រងតាមវិធីដែលសមស្របនិងដែល**ត្រូវគ្នាជាមួយគោលនយោបាយផ្តល់មូលនិធិ និងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួនដែរឬទេ**។ ជាទូទៅ ប្រការនេះរួមបញ្ចូល ការតម្រូវឲ្យមានជាតុនានា ដូចជា ភាពម៉ឺងមាត់ការកសាងផែនការបានគ្រប់គ្រាន់ និងរដ្ឋបាលហិរញ្ញវត្ថុប្រកបដោយតម្លាភាព និងការពិនិត្យតាមដាន និងរាយការណ៍បានច្បាស់លាស់ ចំណែកម្ចាស់ជំនួយខ្លះ (ដូចជា ធនាគារពិភពលោក) ក៏នឹងព្យាយាមរក្សាទុកតួនាទីក្នុងការអនុម័តលើផែនការ និងគោលនយោបាយនានាផងដែរ។ លើសពីនេះ ម្ចាស់ជំនួយអន្តរជាតិពីវិស័យសាធារណៈជាច្រើន ក៏នឹងដាក់

លក្ខខណ្ឌ និងការកំហិតទូទៅរបស់ពួកគេលើការផ្តល់មូលនិធិផងដែរ ដែលជាញឹកញាប់ រួមបញ្ចូលប្រព័ន្ធសុវត្ថិភាពសង្គម/បរិស្ថាន និងគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុផងដែរ។

ដូចដែលបានពិភាក្សាក្នុងផ្នែក ២.៦ខាងលើ ទាក់ទងនឹងប្រព័ន្ធសុវត្ថិភាព មូលនិធិនានាគ្រប់គ្រងលក្ខខណ្ឌទាំងនេះ ដោយអនុវត្តលក្ខខណ្ឌទាំងនោះទៅតាមគម្រោងដាច់ដោយឡែកពីគ្នា ឬ ដោយប្រកាន់យកនីតិវិធីតឹងរ៉ឹងគ្រប់គ្រាន់ដែលបំពេញបានតាមគោលការណ៍របស់ម្ចាស់ជំនួយធំៗភាគច្រើន។

នៅក្នុងករណីមូលនិធិរ៉េដបូកដែលផ្អែកលើគុណផល ម្ចាស់ជំនួយបានបង្ហាញពីភាពទន់ភ្លន់នៅក្នុងវិស័យខ្លះដែលឆ្លុះបញ្ចាំងអំពីការអនុវត្តទៅតាមដំណាក់កាលសម្រាប់មូលនិធិរ៉េដបូក និងកម្រិតខុសៗគ្នានៃ"ការត្រៀមលក្ខណៈ"របស់ប្រទេសនីមួយៗ។ ឧទា. មូលនិធិអាម៉ាហ្សូន និងម្ចាស់ជំនួយ GRIF អនុញ្ញាតឲ្យមានការបង់ថ្លៃដោយគ្មានយោងទៅកម្រិតយោង និងប្រព័ន្ធ MRV ដែលត្រូវដាក់ឲ្យដំណើរការពេញលេញនោះឡើយ ជាជំនួសគឺបានអនុញ្ញាតឲ្យមានការបង្កើត និងកែប្រែប្រព័ន្ធបែបនេះទៅតាមពេលវេលា។ បើទោះជាមានភាពបត់បែនជាទូទៅបែបនេះក៏ដោយ សម្រាប់អ្នកទទួលការបង់ថ្លៃផ្អែកតាមលទ្ធផល ជាញឹកញាប់ ម្ចាស់ជំនួយនៅតែគូសបញ្ជាក់អំពីថាតើមូលនិធិនឹងត្រូវប្រើប្រាស់បែបណា (ដូចជា ដោយវាយតម្លៃកម្មវិធីជាក់លាក់ ឬ យន្តការផ្តល់មូលនិធិ)។

លក្ខខណ្ឌជាក់លាក់របស់ម្ចាស់ជំនួយ ក៏អាចឆ្លុះបញ្ចាំងអំពីកាលៈទេសៈរបស់ជាតិនៅក្នុងប្រទេសជាម្ចាស់ផ្ទះផងដែរ។ នៅប្រទេសហ្គុយយ៉ាណា ភាពទន់ខ្សោយនៃអភិបាលកិច្ច និងហានិភ័យកម្រិតខ្ពស់នៃអំពើពុករលួយ បានតម្រូវឲ្យម្ចាស់ជំនួយទាមទារឲ្យមានកំណែទម្រង់អភិបាលកិច្ច ជាលក្ខខណ្ឌសម្រាប់ការបង់ថ្លៃទៅតាមលទ្ធផល។

នៅទីបំផុត នៅក្នុងករណីខ្លះ ម្ចាស់ជំនួយអាចដាក់លក្ខខណ្ឌដែលលើកកំពស់ផលប្រយោជន៍ជាតិរបស់ខ្លួន ដូចជា ការលើកកំពស់ឲ្យមានធុរកិច្ចរបស់ខ្លួន។ ឧទា. ជំនួយឥតសំណងពីប្រទេសអាល្លឺម៉ង់ដល់ FONAFIFO តម្រូវឲ្យក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវអាកាស ឬ តាមសមុទ្ររបស់អាល្លឺម៉ង់ ទទួលបានឋានានុក្រមពិសេសចំពោះក្រុមហ៊ុនកូស្តារីកា ក្នុងការផ្តល់សេវានានាដែលទទួលមូលនិធិពីជំនួយឥតសំណងនោះ។